ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# លទ្ធផលនៃអង្កេតភពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១

## ( តំបន់ខ្ពង់រាបក្នុងខេត្តកំពង់ធំ និង ខេត្តសៀមរាប )

រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការណ៍ភពផែនដី
វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

ខែ តុលា ឆ្នាំ ២០២១

# និមិត្តសញ្ញាសំគាល់
# ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា

( Cambodia GEO )

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយសូមបង្ហាញជូននូវសមិទ្ធិផលថ្មីមួយទៀតដែលសម្រេចបានរបស់ក្រសួងផែនការនៅក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា គឺរបាយការណ៍លទ្ធផលវិភាគទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១ ដែលបានសិក្សាទៅលើខេត្ត ២ នៅតំបន់ខ្ពង់រាបដែលរួមមាន ខេត្តកំពង់ធំ និងខេត្តសៀមរាប បើទោះបីស្ថិតនៅក្នុងដំណាក់កាលឆ្លងកាត់ការលំបាកនៃការឆ្លងជំងឺរាតត្បាតកូវីដ ១៩ ក៏ដោយ។ ។ អង្កេតភពផែនដី គឺជាអង្កេតលើកទី ៣ ដែលបានដឹកនាំអនុវត្តដោយអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ ២០១៧ រួចមក។

អង្កេតភពផែនដីនេះ គឺបានប្រមូលទិន្នន័យនូវសូចនាករចម្បងៗ ស្តីអំពីស្ថានភាពលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ខ្ពង់រាប នៅក្នុងគោលដៅនៃខេត្តទាំង ២ ខាងលើ។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យនៃអង្កេតនេះ គឺត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ប្រធានភូមិ និងមេគ្រួសារនៅក្នុងតំបន់គោលដៅ ខណៈដែលប្រទេសកម្ពុជាយើងពុំទាន់មានផ្កាយរណប និងពុំមានប្រទេសណាមួយបានផ្តល់នូវទិន្នន័យ តាមរយៈផ្កាយរណបនៅឡើយ។ ថវិកាដែលប្រើប្រាស់នៅក្នុងការធ្វើអង្កេតនេះ គឺបានការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីឆ្នាំ ២០២១ របស់ក្រសួងផែនការ ។

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅជាទីបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព និងការឯកភាពជាតិទូទាំងប្រទេសតាមរយៈគោលនយោបាយ «**ឈ្នះឈ្នះ**» ដែលបានផ្តល់ឱកាសដល់ការងារប្រមូលទិន្នន័យនៅតំបន់គោលដៅប្រកបដោយជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកជំទាវ **ហាន់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឯកឧត្តមបណ្ឌិត **ម៉េង គឹមហ៊ី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងជាប្រធានអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ព្រមទាំងមន្ត្រីថ្នាក់ក្រោមជាតិ ដែលរួមមានមន្ត្រីរបស់មន្ទីរផែនការខេត្តកំពង់ធំ និងខេត្តសៀមរាប ដែលបានចូលរួមក្នុងការប្រមូលទិន្នន័យតាមតំបន់គោលដៅនៅក្នុងខេត្តទាំង ២ ខាងលើនេះ។ ខ្ញុំសូមអរគុណចំពោះការខិតខំប្រឹងប្រែង របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមសកម្មភាពការងារទាំងអស់នេះ។

ជាចុងក្រោយ ខ្ញុំសូមអរគុណ និងកោតសរសើរដល់អង្គភាពក្រុមសង្កេតការណ៍ភពផែនដីដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបំពេញការងារយ៉ាងល្អប្រសើរប្រកបដោយវិជ្ជាជីវៈខ្ពស់ ការប្តេជ្ញាចិត្តមោះមុត និងការលះបង់ដ៏ធំធេង ដើម្បីការងារអង្កេតនេះទទួលបានលទ្ធផលគួរជាទីទុកចិត្តដល់គ្រប់អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ។

ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបាននូវសារៈប្រយោជន៍ពីលទ្ធផលនៃការធ្វើអង្កេតនេះ ដោយប្រើប្រាស់ទិន្នន័យក្នុងអង្កេតកពផែនដី ដើម្បីរៀបចំធ្វើផែនការ និងរៀបចំគោលនយោបាយទាក់ទងទៅនឹងការតាមដានត្រួតពិនិត្យលក្ខណៈប្រជាសាស្ត្រ ផ្នែកបរិស្ថាន ការពារគ្រោះមហន្តរាយ និងមានវិធានការណ៍សមស្របទាក់ទងនឹងការប្រែប្រួលអាកាសធាតុ បន្ថែមពីលើទិន្នន័យដែលបានមកពីប្រភពដទៃទៀត ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ក៏ដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលនៃអង្កេតនេះផងដែរ នៅក្នុងការស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅខាងលើ។

ថ្ងៃ ចន្ទ ៨កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២២

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

របាយការណ៍លទ្ធផលស្តីពីអង្កេតកពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១ នេះបាន ផលិតដោយអង្គភាពក្រុមសង្កេតការណ៍កពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង ផែនការ។ ចាប់តាំងពីប្រទេសកម្ពុជាចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការកពផែនដីនៅឆ្នាំ ២០១៧ មក គម្រោងអង្កេតកពផែនដីនៅព្រះរាជាណាចក្រកម្ពុជានេះ បានចុះស្រង់ទិន្នន័យនៅឆ្នាំ ២០១៩ ដែលមានចំនួនខេត្ត៥ ដែលស្ថិតជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ ២០២១ នេះ ការចុះស្រង់ទិន្នន័យនៅក្នុងតំបន់ ខ្ពង់រាប រួមមានខេត្តកំពង់ធំ និងខេត្តសៀមរាប បានអនុវត្តនៅក្នុងគម្រោងអង្កេតកពផែនដីនៅព្រះរាជា ណាចក្រកម្ពុជាឆ្នាំ ២០២១ ដោយទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាកម្មវិធីប្រចាំ ឆ្នាំរបស់ក្រសួងផែនការ ។

គោលបំណងចម្បងនៃអង្កេតនេះគឺដើម្បីប្រមូលនូវសូចនាករសំខាន់ៗទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសន៍មេភូមិ និងមេគ្រួសារ ជំនួសឲ្យការទទួលបានទិន្នន័យពីផ្កាយរណប និងឧបករណ៍ថតរូបភាពផ្សេងៗ ដែលថតពីលើ អាកាស ខណៈដែលបច្ចុប្បន្នការប្រមូលទិន្នន័យបែបនេះ ពុំទាន់មានលទ្ធភាពធ្វើទៅបាន។ លទ្ធផល នៃអង្កេតកពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១ នេះ រួមមានរបាយការណ៍លទ្ធផលអង្កេត ជាឯកសារបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ហើយក៏មានដាក់ចូលនៅក្នុងគេហទំព័ររបស់ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទៀតផង។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានផ្តល់អនុសាសន៍ល្អៗ និងជំរុញលើកទឹកចិត្ត ដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានចូលរួមនៅក្នុងការអនុវត្តគម្រោងរហូតទទួលបាន ជោគជ័យ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **លោកជំទាវ ហង់ លីណា** ប្រតិភូរាជ រដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានយកចិត្តទុកដាក់ និងបាន ណែនាំដល់មន្ត្រីចុះស្រង់ទិន្នន័យ និងកែច្នៃទិន្នន័យឲ្យមានគុណភាពល្អ និងឯកឧត្តមប្រធានមន្ទីរ ផែនការខេត្តទាំង ២ រួមមាន ខេត្តកំពង់ធំ និងខេត្តសៀមរាប ដែលបានសហការល្អនៅក្នុងអំឡុងពេល ចុះស្រង់ទិន្នន័យនៅតាមបណ្តាខេត្តពាក់ព័ន្ធខាងលើ។

តាងនាមឲ្យអង្គភាពក្រុមសង្កេតការណ៍កពផែនដីកម្ពុជា នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សូមស្វាគមន៍ចំពោះការចង់បាននូវព័ត៌មានបន្ថែមអំពីការធ្វើអង្កេតនេះ។

ថ្ងៃ ចន្ទ ៨កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២២*

**អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ និង ជា**

**ប្រធានអង្គភាពក្រុមសង្កេតការណ៍កពផែនដីកម្ពុជា**

បណ្ឌិត **ម៉េង គឹមហ៊ា**

# មាតិកា

ទំព័រ

និមិត្តសញ្ញាសំគាល់ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា .......... i
បុព្វកថា .......... ii
អារម្ភកថា .......... iv
**ជំពូក ១ សេចក្តីផ្តើម** .......... ១
១.១ សេចក្តីផ្តើម .......... ១
១.២ គោលបំណង .......... ២
១.៣ វិធីសាស្រ្តប្រមូលទិន្នន័យ .......... ២
១.៤ ការកែច្នៃទិន្នន័យ .......... ៣
១.៥ សារៈប្រយោជន៍ .......... ៣
**ជំពូក ២ ស្ថានភាពទូទៅ** .......... ៤
២.១ ប្រជាសាស្រ្ត .......... ៤
២.១.១ និន្នាការចំនួនប្រជាជន .......... ៤
២.១.២ ដង់ស៊ីតេប្រជាជន .......... ៧
២.១.៣ ការបំលាស់ទីកន្លែងរស់នៅ .......... ១០
២.១.៤ ការងារ និងសេដ្ឋកិច្ច .......... ១៦
២.២. ទីប្រជុំ គ្រួសារ អាគារ និងលំនៅដ្ឋាន .......... ២២
២.២.១ ទីប្រជុំជន .......... ២២
២.២.២ គ្រួសារ និងអាគារ .......... ២៥
២.២.៣ លំនៅដ្ឋាន .......... ២៦
២.៣ បរិស្ថាន ទឹកស្អាត និងបង្គន់អនាម័យ .......... ២៩
២.៣.១ បរិស្ថាន .......... ២៩
២.៣.២ ទឹកស្អាត និងទឹកកខ្វក់ .......... ៣៨
២.៣.៣ បង្គន់អនាម័យ .......... ៤២
២.៤ គ្រោះមហន្តរាយ .......... ៤៤
២.៤.១ គ្រោះមហន្តរាយធម្មជាតិ .......... ៤៥
២.៤.២ គ្រោះអគ្គីភ័យ .......... ៤៨
២.៤.៣ ជំងឺឆ្លង .......... ៥០
២.៥ ការប្រែប្រួលអាកាសធាតុ .......... ៥២
២.៥.១ ស្ថានភាពទឹកភ្លៀង .......... ៥៤
២.៥.២ សីតុណ្ហភាព .......... ៥៦

២.៥.៣ កម្ពស់ទឹក ........................................................................................ ៥៧
**ជំពូក ៣ ការវិភាគលទ្ធផល** ...................................................................... ៦០
៣.១ ព័ត៌មានទូទៅ ............................................................................................ ៦០
៣.១.១ គ្រួសារ ................................................................................................ ៦០
៣.១.២ ទំហំគ្រួសារ ........................................................................................ ៦១
៣.១.៣ ចំណាកស្រុក ...................................................................................... ៦៣
៣.១.៤ ការចូលរួមកម្លាំងពលកម្ម ................................................................... ៦៧
៣.២ បរិស្ថាន ..................................................................................................... ៦៩
៣.២.១ បង្គន់អនាម័យ ...................................................................................... ៦៩
៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និង ផលប៉ះពាល់ពីការចាក់សំរាម ..... ៧០
៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត ..................................... ៧១
៣.៣ គ្រោះមហន្តរាយ ......................................................................................... ៧២
៣.៤ ការប្រែប្រួលអាកាសធាតុ ............................................................................. ៧៥
៣.៤.១ ស្ថានភាពទឹកភ្លៀង................................................................................... ៧៥
៣.៤.២ ស្ថានភាពសីតុណ្ហភាព ............................................................................ ៧៥
**ជំពូក ៤ របកគំហើញ និង សន្និដ្ឋាន** ............................................................. ៧៧
៤.១ របកគំហើញ ............................................................................................... ៧៧
៤.១.១ កំណើនប្រជាជន ការធ្វើចំណាកស្រុក និងការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច ........................................................................... ៧៧
៤.១.២ តំបន់ទីប្រជុំជនមានការកើនឡើង ........................................................... ៧៧
៤.១.៣ បរិស្ថាន ................................................................................................ ៧៨
៤.១.៤ គ្រោះមហន្តរាយ ..................................................................................... ៧៨
៤.១.៥ ការប្រែប្រួលអាកាសធាតុ ........................................................................ ៧៩
៤.២ សន្និដ្ឋាន .................................................................................................... ៧៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺត្រូវបាននាយកលេខាធិការនៃលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ភពផែនដី ប្រកាសជាផ្លូវការចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាលើកទី១៤ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២៥ ដល់ ២៦ ខែ តុលា ឆ្នាំ២០១៧ នៅទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ដែលមានវត្តមាន **ឯកឧត្តម ជុំ ប៊ុនរ៉ុង** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក តំណាងឲ្យប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមពីលេខាទី១របស់ស្ថានទូត និងមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការតាមរយៈសំណើរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៧ ទៅនាយកលេខាធិការនៃលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ភពផែនដី (GEO) ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ បន្ទាប់ពីបានចូលជាសមាជិកក្រុមសង្កេតការណ៍ភពផែនដីជាផ្លូវការរួចមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលធ្វើកិច្ចការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋានក្រុមសង្កេតភពផែនដី ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវប្រទេសស្វីស ។ ការងារសំខាន់របស់ប្រទេសជាសមាជិកក្រុមសង្កេតការភពផែនដី គឺសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យ ដែលបានមកពីផ្កាយរណប ឬ ឧបករណ៍ផ្សេងៗ ដែលថតរូបភាពពីលើអាកាស សម្រាប់ធ្វើការតាមដានត្រួតពិនិត្យបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។ ដោយឡែក ចំពោះប្រទេសកម្ពុជា ពេលបច្ចុប្បន្ននេះ ពុំមានផ្កាយរណប ឬ ឧបករណ៍ថតពីលើអាកាសទេ ឬ ទទួលបានការចែករំលែកទិន្នន័យពីផ្កាយរណបពីបណ្តាប្រទេសផ្សេងទៀតដែលមានផ្កាយរណប។ ហេតុដូច្នេះ ជំនួសការប្រមូលទិន្នន័យត្រូវធ្វើតាមរយៈការសម្ភាសន៍មេភូមិ និង មេគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅនោះវិញ។ សម្រាប់ការអនុវត្តការងារជំហានទី១ នៅឆ្នាំ២០១៩ អង្គភាពក្រុមសង្កេតការណ៍ភពផែនដី បានអនុវត្តគម្រោងសកម្មភាពការងារ ដែលបានផ្តោតទៅលើខេត្ត៥ នៅជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដោយប្រើប្រាស់ថវិកាពរាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីរបស់ក្រសួងផែនការដែលមានចំនួនកំណត់។ នៅក្នុងការអនុវត្តការងារជំហានទី២ ឆ្នាំ ២០២០ សកម្មភាពចុះស្រង់ទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងតំបន់ខ្ពង់រាបនៅក្នុងខេត្ត ៣ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលគម្រោងអនុវត្ត ៥ ខេត្តដូចឆ្នាំ ២០១៩ ដែរ តែដោយសារបញ្ហាជំងឺឆ្លងកូវីដ ១៩ ត្រូវបានរាជរដ្ឋាភិបាលឲ្យកាត់សកម្មភាព ៥០ភាគរយ។នៅក្នុងឆ្នាំ ២០២១ នេះ រាជរដ្ឋាភិបាលបានកាត់ថវិកាគ្រប់គម្រោងទាំងអស់ ៣៧,៥% លើគម្រោងដែលបានកាត់ ៥០% ប៉ុន្តែសកម្មចុះស្រង់ទិន្នន័យនៅក្នុងខេត្ត

២ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាបគឺ ខេត្តកំពង់ធំ និងខេត្តសៀមរាប ពុំទាន់បានអនុវត្តនៅឡើយ ហើយគម្រោងចុះអនុវត្តនៅក្នុងខេត្តទាំង២នេះ នៅក្នុងឆ្នាំនេះដដែល ប៉ុន្តែការសម្ភាសន៍មេគ្រួសារមានចំនួនតិចជាងមុនដោយសារការកាត់បន្ថយថវិកា។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការអនុវត្តគម្រោងនេះ គឺការកសាងប្រព័ន្ធទិន្នន័យស្ថិតិទាក់ទងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ខ្ពង់រាបនៅក្នុងខេត្ត ២ គឺខេត្តកំពង់ធំ និងខេត្តសៀមរាប ដើម្បីចូលរួមតាមដានលើការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៣ វិធីសាស្រ្តប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ធ្វើការវិភាគនេះ គឺបានមកពីការប្រមូលទិន្នន័យពីរប្រភេទ គឺទិន្នន័យទី១ និងទិន្នន័យទី២។ វិធីសាស្រ្តនៃការប្រមូលទិន្នន័យទី១ គឺត្រូវបានប្រមូលតាមរយៈការធ្វើសម្ភាសន៍មេភូមិ និងមេគ្រួសារនៅក្នុងភូមិគោលដៅនៃខេត្តទាំង ២ ស្ថិតនៅតំបន់ខ្ពង់រាប។ កម្រងសំណួរសម្រាប់សម្ភាសន៍មានពីរ គឺកម្រងសំណួរសម្រាប់សម្ភាសន៍មេភូមិ និងកម្រងសំណួរសម្រាប់សម្ភាសន៍មេគ្រួសារ ។ ចំនួនភូមិគោលដៅ ៨ភូមិ និង ចំនួនមេគ្រួសារ ៥៦០ នាក់ ស្ថិតនៅក្នុងខេត្ត២ ស្ថិតក្នុងតំបន់ខ្ពង់រាប គឺត្រូវបានធ្វើសម្ភាសន៍។ ទិន្នន័យទី ២ គឺត្រូវបានប្រមូលពីក្រសួងបរិស្ថាន ក្រសួងធនធានទឹក និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលបានផលិតចេញជារបាយការណ៍ផ្សេងៗ។

តារាង ១.១ បង្ហាញពីបញ្ជីភូមិគោលដៅ សម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យ នៅក្នុងខេត្ត ២ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប រួមមានខេត្តកំពង់ធំ និងខេត្តសៀមរាប។

**តារាង ១.១ បញ្ជីភូមិសម្រាប់សម្ភាសន៍**

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កំពង់ធំ | ស្រុកស្ទឹងសែន | ស្រយ៉ូវ | ពុកពុយ | 540 | 60 |
| | | | អាចារ្យលាក់ | ក្រចាប់ | 739 | 60 |
| | | កំពង់ស្វាយ | ត្រពាំងឫស្សី | ថ្នល់បំបែក <ក> | 258 | 60 |
| | | | ត្បែង | បាគង | 279 | 60 |
| ២ | សៀមរាប | អង្គរធំ | លាងដៃ | បំពេញរាជ្យ | 223 | 60 |
| | | | ពាក់ស្នែង | ដប់សោម | 171 | 60 |
| | | បន្ទាយស្រី | ព្រះដាក់ | តាកុះ | 431 | 60 |
| | | | ខ្នារសណ្តាយ | ប្រី | 209 | 60 |
| **សរុប** | | | | | **2,850** | **480** |

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យដែលបានមកពីការធ្វើសម្ភាសន៍តាមរយៈមេភូមិ និង មេគ្រួសារនៅតាមភូមិគោលដៅនៅក្នុងខេត្តទាំង ៣ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប គឺត្រូវបានវាយបញ្ចូលទៅក្នុងកុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី CSPro 7.4 និងការពិនិត្យកំហុស និងការផលិតជាតារាងសម្រាប់ធ្វើការវិភាគក៏បានប្រើប្រាស់កម្មវិធី CSPro 7.4 នេះផងដែរ ។ ចំពោះកម្មវិធី Microsoft Excel គឺត្រូវបានប្រើប្រាស់សម្រាប់ការធ្វើក្រាហ្វិក និង កម្មវិធី Microsoft Word គឺសម្រាប់សរសេររបាយការណ៍វិភាគទិន្នន័យ។

## ១.៥ សារៈប្រយោជន៍

របាយការណ៍វិភាគទិន្នន័យនេះ គឺមានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយផ្សេងៗ ជាពិសេសរាជរដ្ឋាភិបាលមានទិន្នន័យបន្ថែមទៀតសម្រាប់រៀបចំគោលនយោបាយទាក់ទងទៅនឹងការត្រួតពិនិត្យតាមដានលើផ្នែកបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុតាមតំបន់នីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានវិធានការបង្ការនូវហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

# ជំពូក ២
# ស្ថានភាពទូទៅ

## ២.១ ប្រជាសាស្ត្រ



### ២.១.១ និន្នាការចំនួនប្រជាជន

ចំនួនប្រជាជនសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញតាមរយៈការធ្វើជំរឿនប្រជាជនឆ្នាំ ១៩៦២ មានចំនួន៥,៧ លាននាក់ បានកើនឡើងដល់ចំនួន ១១,៤ លាននាក់ ផ្អែកតាមការធ្វើជំរឿនប្រជាជនឆ្នាំ ១៩៩៨ រយៈពេល៣៦ឆ្នាំនេះប្រជាជនកម្ពុជា បានកើនឡើងជាង២ដងស្មើនឹងចំនួន៧,៧ លាននាក់ ។ ចំនួនប្រជាជនក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៨ មានការកើនឡើងប្រហែលចំនួន ២លាននាក់ (៩,៥%) ហើយក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៩ កើនឡើងចំនួន ១,៩លាននាក់ (១៤,១%) នឹងត្រូវបានគេរំពឹងទុកថានៅឆ្នាំ ២០៣០ ចំនួនប្រជាជនកម្ពុជាអាចកើនដល់ ១៨,៤លាននាក់។ ក្រាហ្វិក២.១ បង្ហាញអំពីនិន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេសផ្អែកតាមទិន្នន័យអង្កេត និង ជំរឿនប្រជាជនតាមបណ្ដាឆ្នាំ។

## ក្រាហ្វិក ២.១ និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេស




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*

*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*

*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*

*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

ចំនួនប្រជាជននៃខេត្តទាំងពីរមានការកើនឡើងពី ១,៣ លាននាក់ នៅឆ្នាំ ១៩៩៨ កើនឡើងដល់ ២,២ លាននាក់នៅឆ្នាំ ២០៣០ ។ នៅក្នុងនោះ ខេត្តកំពង់ធំបានកើនឡើងប្រហែល១៥ ម៉ឺននាក់ ក្នុងរយៈពេល៣២ឆ្នាំ បើគិតពីឆ្នាំ ១៩៩៨ ដល់ ២០៣០ ខណៈដែលខេត្តសៀមរាបមានការកើនឡើងប្រហែល ៧២ ម៉ឺននាក់ នៅក្នុងឆ្នាំដូចគ្នានេះដែរ។

## ក្រាហ្វិក ២.២ និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពង់ធំ និងខេត្តសៀមរាប




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

តារាង ២.១ ខាងក្រោមបង្ហាញអំពី ចំនួនប្រជាជនខេត្តកំពង់ធំ ខេត្តសៀមរាប និងទូទាំងប្រទេសកម្ពុជា ពីឆ្នាំ ១៩៩៨ ដល់ ២០៣០។ ចំនួនភាគរយប្រជាជនខេត្តកំពង់ធំបានកើនឡើងពីឆ្នាំ ១៩៩៨ ដល់២០០៨ មានចំនួន ១១ ភាគរយ ខេត្តសៀមរាបមានចំនួន ២៩ ភាគរយ និងកម្ពុជាមានចំនួន ១៧ភាគរយ។ បើប្រៀបធៀបពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១៩ ចំនួនភាគរយប្រជាជនខេត្តកំពង់ធំបានកើនឡើងពីឆ្នាំ ២០០៨ ដល់២០១៩ មានចំនួន ៨ ភាគរយ ខេត្តសៀមរាបមានចំនួន ១៣ ភាគរយ និងកម្ពុជាមានចំនួន ១៦ភាគរយ និងចាប់ពីឆ្នាំ ២០១៩ ដល់ ឆ្នាំ ២០៣០ ចំនួនប្រជាជនខេត្តកំពង់ធំកើនឡើងមានចំនួន ៦ ភាគរយ ខេត្តសៀមរាបមានចំនួនកើនឡើងខ្ពស់ដល់៣៩ភាគរយ និងកម្ពុជាកើនឡើង ១៨ ភាគរយ។

តារាង ២.១ ចំនួនប្រជាជនសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣០ គិតជានាក់

| ឆ្នាំ | កំពង់ធំ | សៀមរាប | កម្ពុជា |
|---|---|---|---|
| 1998 | 569,060 | 696,164 | 11,437,656 |
| 2004 | 607,000 | 755,000 | 12,824,000 |
| 2008 | 631,409 | 896,443 | 13,395,682 |
| 2013 | 690,414 | 922,982 | 14,676,591 |
| 2019 | 681,549 | 1,014,234 | 15,552,211 |
| 2025 | 716,222 | 1,319,807 | 17,519,272 |
| 2030 | 724,456 | 1,414,727 | 18,390,683 |

*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

## ២.១.២ ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជនជាសូចនាករមួយយ៉ាងសំខាន់សម្រាប់ពិនិត្យមើលរបាយប្រជាជនតាមតំបន់ រាជធានី ខេត្ត ។ ដង់ស៊ីតេចំនួនប្រជាជនទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ មានដង់ស៊ីតេចំនួន ៦៤នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ហើយបានកើនឡើង ៧៥ ក្នុងមួយគីឡូម៉ែត្រក្រឡា និង កើនឡើងដល់ ៨៦ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡានៅឆ្នាំ២០១៩ ខណៈដែលខេត្តទាំង ៣ មានដង់ស៊ីតេចំនួន ៥៣ នាក់ក្នុង មួយគីឡូម៉ែត្រក្រឡា នៅឆ្នាំ ១៩៩៨ នឹងកើនឡើងដល់ ៦៤ នាក់ក្នុងមួយគីឡូម៉ែត្រក្រឡានៅឆ្នាំ ២០១៩។ ចំណែក ឯនៅក្នុងតំបន់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៥៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ក្នុងឆ្នាំ ២០០៨ និង បានកើនឡើង ៦២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០១៩។ ចំណែកឯខេត្ត ទាំង ៥ ជាប់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៦៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើង ដល់ ៧៣នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅក្នុងឆ្នាំ ២០១៩ ខណៈខេត្តទាំង ៣ មារួមមាន ខេត្តកំពង់ឆ្នាំង ពោធិសាត់ និងខេត្តបាត់ដំបងមានចំនួន ៧០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

## រូបភាព ២.៣ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ១៩៩៨




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ១៩៩៨

## រូបភាព ២.៤ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០០៨




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ២០០៨

# រូបភាព ២.៥ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០១៩




ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

# រូបភាព ២.៦ ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តសៀមរាប ឆ្នាំ ២០១៩




ប្រភព៖ របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

រូបភាព ២.៧ ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកំពង់ធំ ឆ្នាំ ២០១៩




ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

## ២.១.៣ ការបំលាស់ទីកន្លែងរស់នៅ

សូចនាករការបំលាស់ទីកន្លែងរស់នៅដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចង់បង្ហាញអំពីការបំលាស់ទីកន្លែងរស់នៅរបស់ប្រជាជន ដែលភាគច្រើនគឺការផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារបញ្ហាសេដ្ឋកិច្ច។ ប្រជាជនកម្ពុជាភាគច្រើន គឺជាអ្នកប្រកបរបរកសិកម្ម តែដោយដោយសារកំណើនប្រជាជន សំណង់លំនៅដ្ឋានមានការកើនឡើង ហើយផ្ទៃដីកសិកម្មត្រូវបានរួមតូចដោយសារការអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្ម ប្រជាជនដែលមានចំណេះដឹងតិចតួច ដែលចេះតែធ្វើការងារកសិកម្មហើយពុំមានផ្ទៃដីគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្ម បានស្វែងរកទីកន្លែងរស់នៅថ្មី ដែលពួកគាត់គិតថាមានភាពប្រសើរជាងមុន ជាពិសេសនៅតំបន់ប៉ែកឦសាន ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តដទៃទៀត។ ខេត្តកំពង់ធំ និងខេត្តសៀមរាប កាលពីមុន គឺជាខេត្តសម្បូរព្រៃឈើ ត្រី និង ដីកសិកម្មទូលំទូលាយ ព្រមទាំងមានស្ថានភាពភូមិសាស្ត្រល្អ ដល់ប្រជាជនដែលចង់ប្រកបរបរកសិកម្មអាចរស់នៅបាន។ ដូច្នេះ ប្រជាជនភាគច្រើននៅតំបន់ទំនាបកណ្តាល បានផ្លាស់ប្តូរទីកន្លែងរស់នៅតំបន់ទាំងនោះ។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា គឺត្រូវបានកំណត់ជាដំណើរការនៃការផ្លាស់ប្តូរកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ បានឲ្យគ្រប់ប្រទេសទាំងអស់លើពិភពលោកបញ្ចូលសូចនាករនេះទៅក្នុងតារាងបញ្ជីសំណួរនៃការធ្វើជំរឿនប្រជាជន ដើម្បីសិក្សាអំពីចរិកលក្ខណៈនៃ

ការផ្លាសប្តូរលំនៅដ្ឋាន។ ជាក់ស្តែងផងដែរ រាជរដ្ឋាភិបាលកម្ពុជាមានទិន្នន័យ សម្រាប់ការរៀបចំគោលនយោបាយជាតិទាក់ទងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងរកវិធីសាស្ត្រណាទប់ស្កាត់ការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងបង្កើតការងារនៅក្នុងស្រុក ឬ នៅទីតាំងជិតលំនៅដ្ឋានរបស់ពួកគាត់តែម្តង ។ នៅឆ្នាំ ១៩៩៨ ប្រជាជនទូទាំងប្រទេសមានការផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣១ភាគរយ ហើយបានកើនឡើង ៣៥ភាគរយនៅឆ្នាំ ២០០៤ ប៉ុន្តែនៅឆ្នាំ ២០០៨ បានធ្លាក់ចុះមកត្រឹម ២៦,៥ភាគរយ និងបានកើនឡើងវិញនៅឆ្នាំ ២០១៣ មានចំនួន ២៨,៩ ភាគរយ និងបានធ្លាក់ចុះមកត្រឹម ២១,៥ភាគរយ នៅឆ្នាំ ២០១៩។ សូចនាកររករនេះ ប្រសិនបើពិនិត្យឲ្យស៊ីជម្រៅ វាមានទំនាក់ទំនងទៅការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងមូលដ្ឋានផ្ទាល់ ដូចជាការងារកសិកម្មដែលជាការងារជាប្រពៃណីរបស់ប្រជាជនកម្ពុជាភាគច្រើន ដែលពួកគាត់បានធ្វើរាប់ជំនាន់មកហើយ តែដោយសារដីកសិកម្មរួមតូច ពួកគាត់ត្រូវធ្វើចំណាកស្រុកទៅតំបន់ផ្សេង ជាពិសេសតំបន់ដែលសម្បូរព្រៃឈើ ដើម្បីធ្វើកសិកម្ម ពួកគាត់ត្រូវកាប់ព្រៃឈើ រានយកដី ដែលធ្វើប៉ះពាល់បរិស្ថាន ប៉ះពាល់ដល់ជីវចម្រុះផ្សេងៗ គួបផ្សំនឹងការបាត់បង់ព្រៃឈើស្រាប់ផងនោះ បានធ្វើឲ្យព្រៃឈើមានការបាត់បង់បន្ថែមទៀត ដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ ទឹកជំនន់ គ្រោះរាំងស្ងួត ជាដើម។

**រូបភាព ២.៨ ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជនកម្ពុជា នៅតាមតំបន់ទីប្រជុំជន គឺមានចំនួនច្រើនជាងតំបន់ជនបទទាំងនៅឆ្នាំ ២០០៨ និង ២០១៣ ។ នៅឆ្នាំ ២០០៨ ប្រជាជនដែលបានផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៥៩,៧ភាគរយ ហើយបានថយចុះនៅឆ្នាំ ២០១៣ ដែលមានចំនួន ៤៩,៤ភាគរយ ខណៈដែលតំបន់ជនបទនៅឆ្នាំ ២០០៨ មានចំនួន ១៨,៩ ភាគរយ ហើយបានកើនឡើងដល់ ២៣,៣ ភាគរយ នៅឆ្នាំ ២០១៣ និងបានធ្លាក់ចុះមកត្រឹម ១២,៤ភាគរយ នៅឆ្នាំ ២០១៩។

**រូបភាព ២.៨ ការផ្លាស់ប្តូរទីលំនៅតាមតំបន់ទូទាំងប្រទេស**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨

- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨

- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាពស្រ្តកម្ពុជាឆ្នាំ ២០១៣

- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

និន្នាការនៃការផ្លាស់ប្តូរទីលំនៅពីមុននៅប្រទេសកម្ពុជាមានការថយចុះពី ៣១ ភាគរយ នៅឆ្នាំ ១៩៩៨ មកត្រឹម ២២ភាគរយ នៅឆ្នាំ ២០១៩ ខណៈដែលនៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប ក៏មាននិន្នាការដូចគ្នាដែរ។ នៅក្នុងខេត្តកំពង់ធំ ការផ្លាស់ប្តូរទីលំនៅពីមុន មានចំនួន ១៨ ភាគរយ នៅឆ្នាំ ១៩៩៨ និងបានថយចុះមកត្រឹម ១០ ភាគរយ និង ខេត្តសៀមរាបមានចំនួន ២៧ភាគរយ នៅឆ្នាំ ១៩៩៨ និងបានថយចុះមកត្រឹម ១៦ភាគរយ នៅឆ្នាំ ២០១៩ ច្រើនជាងខេត្តកំពង់ធំ ៦ ភាគរយ។ ស្ថានភាពជារួមបានបង្ហាញថា ប្រជាជនមានចំនួនតិចទៅៗ នៅក្នុងការប្តូរទីលំនៅពីមុន ប្រហែលជាពួកគាត់គិតថា ការផ្លាស់ប្តូរការរស់នៅនៅកន្លែងផ្សេងមានលក្ខណៈប្រហែលកន្លែង ដែលពួកគាត់រស់នៅពីមុន។ ដូច្នេះ ពួកគាត់គិតថា ការរកការងារធ្វើនៅកន្លែងផ្សេងមិនមានភាពប្រសើរឡើយ ជាជាងរកការងារនៅកន្លែងបច្ចុប្បន្ន។ ម្យ៉ាងទៀត ការងារនៅទីជនបទ និងទីប្រជុំជន មានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយសារការអភិវឌ្ឍតាមរយៈកម្មវិធីអភិវឌ្ឍន៍ឃុំ សង្កាត់របស់រាជរដ្ឋាភិបាល។

**រូបភាព ២.៩ ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស ខេត្តកំពង់ធំ និង ខេត្តសៀមរាប**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩

នៅក្នុងឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ មូលហេតុចម្បងនៃការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនមានចំនួនច្រើនជាងគេក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ នៅឆ្នាំ ១៩៩៨ មូលហេតុគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣៧,០ ភាគរយ បានកើនឡើងដល់ ៣៧,៩ ភាគរយ នៅឆ្នាំ ២០០៨ និងកើនឡើងដល់ ៣៨,៩ភាគរយ ។ មូលហេតុរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០១៩ មានចំនួនច្រើនជាង ឆ្នាំ ២០០៨ ចំនួន ៥,១ ភាគរយ ហើយមូលហេតុ កូនកំព្រាក៏មានចំនួនថយចុះពី ៥,៦ ភាគរយ នៅឆ្នាំ ២០០៨ មកត្រឹម ០,២ ភាគរយ នៅឆ្នាំ ២០១៩។ មូលហេតុនៃការស្វែងរកការងារធ្វើបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០០៨ មានចំនួន ២១,៥ភាគរយ បានធ្លាក់ចុះ មកត្រឹម ១៩,៦ ភាគរយ ខណៈនៅឆ្នាំ ១៩៩៨ មានចំនួន ១៤,៥ ភាគរយ។ មូលហេតុផ្សេងៗ គឺបានបញ្ចូលនូវមូលហេតុផ្លាស់លំនៅដ្ឋានក្រៅពីមូលហេតុរៀបរាប់ខាងលើ។

**រូបភាព ២.១០ មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ទូទាំងប្រទេស**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

មូលហេតុនៃការផ្លាស់ប្តូរលំនៅដ្ឋាន និងរៀបអាពាហ៍ពិពាហ៍ នៅខេត្តកំពង់ធំនៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប មានចំនួនភាគរយច្រើនជាងមូលហេតុដទៃទៀត ខណៈដែលមូលហេតុដោយការសិក្សាមានចំនួនតិចជាងគេ។ មូលហេតុដោយសារការស្វែងរកការងារធ្វើ និងប្តូរទីកន្លែងការងារមានចំនួនប្រហាក់ប្រហែលគ្នា គឺមានច្រើនជាង១០ភាគរយបន្តិច។

**រូបភាព ២.១១ មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ខេត្តកំពង់ធំ និង ខេត្តសៀមរាប ឆ្នាំ ២០១៩**




សំគាល់÷ ផ្សេងៗរួមមាន បាត់បង់ផ្ទះសម្បែង/ដីធ្លី, រស់នៅកន្លែងផ្សេងដោយកសាងសង់ទិនប់, រស់នៅកន្លែងផ្សេងដោយការអនុវត្តគម្រោងអភិវឌ្ឍន៍, អសន្តិសុខ, វិលត្រលប់មកភូមិកំណើត/មាតុភូមិនិវត្តន៍, កូនចិញ្ចឹម, មកលេងគ្រួសារ, ផ្សេងៗ, មិនបានបញ្ជាក់។

ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

## ២.១.៤ ការងារ និងសេដ្ឋកិច្ច




ប្រជាជនកម្ពុជាអ្នកមានការងារធ្វើសម្រាប់ទូទាំងប្រទេសមានចំនួនលើសពី ៩០ ភាគរយ ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ២០១៩ ។ នៅក្នុងឆ្នាំ ១៩៩៨ អ្នកមានការងារធ្វើមានចំនួន ៩៤,៧ ភាគរយ នៅឆ្នាំ២០០៨ បានកើនឡើងដល់ ៩៨,៣ ភាគរយ និងនៅឆ្នាំ ២០១៩ បានកើនឡើងដល់ ៩៩,១ ភាគរយ ។ អត្រាអ្នកគ្មានការងារធ្វើនៅឆ្នាំ ១៩៩៨ មានចំនួន ៥,៣៤ ភាគរយ ច្រើនជាងឆ្នាំ ២០០៨ ដែលមានចំនួន ១,៧ ភាគរយ និងឆ្នាំ ២០១៩ មានចំនួន ០,៩ ភាគរយ ។ នៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាបក៏មានការធ្លាក់ចុះផងដែរក្នុងនោះ ខេត្តកំពង់ធំនៅឆ្នាំ ១៩៩៨ មានចំនួន ៨,២ភាគរយ និងបានធ្លាក់ចុះមកត្រឹម ០,៦ភាគរយនៅឆ្នាំ ២០១៩ ខណៈដែលខេត្តសៀមរាបក៏មាការធ្លាក់ចុះពី ៤,៦ ភាគរយ នៅឆ្នាំ ១៩៩៨ មកត្រឹម ១,១ភាគរយ នៅឆ្នាំ ២០១៩។

រូបភាព ២.១២ អត្រាអ្នកគ្មានការងារធ្វើ




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨

- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨

- របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

សូចនាករអត្រាអ្នកមានការងារធ្វើនេះ ក៏បានឆ្លុះបញ្ចាំងអំពីការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ចដូចជាវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសេវាកម្ម ។ ប្រសិនបើគិតឲ្យកាន់តែស៊ីជម្រៅ សូចនាករនេះក៏បង្ហាញនូវការពាក់ព័ន្ធនឹងផ្នែកបរិស្ថាន ដូចជាកាលណាប្រជាចូលរួមផ្នែកឧស្សាហកម្មគឺមានចំនួនច្រើនមានន័យថា ផ្នែកផលិតមានការរីកចម្រើន ដែលមានដូចជារោងសិប្បកម្ម រោងចក្រ សហគ្រាសផលិតផ្សេងៗ ហើយការបង្ហូរទឹកចេញពីរោងចក្រចូលទៅក្នុងបឹងធម្មជាតិមានគ្រប់គ្រងបានល្អឬទេ ផលប៉ះពាល់បរិស្ថាន និងការគ្រប់គ្រងវិស័យកសិកម្មធ្វើយ៉ាងណាឲ្យមានប្រសិទ្ធិភាពខ្ពស់ប្រកបដោយចីរភាព។

អត្រាអ្នកមានការងារធ្វើ ត្រូវបានបែងចែកតាមវិស័យសេដ្ឋកិច្ចចម្បងៗរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ នៅក្នុងឆ្នាំ១៩៩៨ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានចំនួន ៧៧,៥ ភាគរយ ហើយបានថយចុះមកត្រឹម ៧២,៣ ភាគរយ នៅឆ្នាំ ២០០៨ និងបន្តធ្លាក់ចុះមានចំនួន៥៤,០ភាគរយ នៅឆ្នាំ២០១៩ ខណៈដែលអត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មមានការកើនឡើង។ នៅក្នុងឆ្នាំ ២០០៨ អត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មមានចំនួន ៨,៥ ភាគរយ និង វិស័យសេវាកម្មមានចំនួន ១៩,២ ភាគរយ និងនៅឆ្នាំ ២០១៩ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មមានចំនួន ១៨,៦ ភាគរយ និង វិស័យសេវាកម្មមានចំនួន ២៧,៤ ភាគរយ ។

**រូបភាព ២.១៣ ការបែងចែកភាគរយអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ចទូទាំងប្រទេស**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ធំ ឆ្នាំ ២០១៩ មានប្រហែល ៧៧ភាគរយ នៅក្នុងវិស័យកសិកម្ម ខ្ពស់ជាងខេត្តសៀមរាបមានចំនួន ៦២ភាគរយ តែវិស័យសេវាកម្ម មានចំនួន ១៦ភាគរយ ទាបជាងខេត្តសៀមរាប មានចំនួន ២៨ ភាគរយ ខណៈទូទាំងប្រទេសមាន ចំនួន៥៤ ភាគរយ ទាបជាង ខេត្តទាំងពីរ និងផ្នែកសេវាកម្មប្រហាក់ប្រហែលខេត្តសៀមរាប តែខ្ពស់ជាងខេត្តកំពងធំ។ ការចូលរួមកម្លាំងពលកម្មនៅទូទាំងប្រទេសមានចំនួន ១៩ ភាគរយ ខ្ពស់ជាង ខេត្តសៀមរាប និងខេត្តកំពង់ធំ។

**រូបភាព ២.១៤ ការបែងចែកកម្លាំងពលកម្មជាភាគរយអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ចឆ្នាំ ២០១៩**




ប្រភព÷ - របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

រូបភាព ២.១៤(ក) បង្ហាញអំពីនិន្នាការនៃការបែងចែកភាគរយអ្នកមានការងារធ្វើតាមវិស័យ សេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ធំពីឆ្នាំ ១៩៩៨ ដល់ ២០១៩ ផ្អែកតាមលទ្ធផលជំរឿនប្រជាជនឆ្នាំ ១៩៩៨ ២០០៨ និង ២០១៩ កន្លងមក។ លទ្ធផលបានបង្ហាញថា ការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្ម មានការថយចុះពី ៨៦,៤ ភាគរយ នៅឆ្នាំ ១៩៩៨ មកត្រឹម ៧៦,៦ ភាគរយនៅឆ្នាំ ២០១៩ ខណៈ ដែលការចូលរួមកម្លាំងពលកម្ម នៅក្នុងវិស័យឧស្សាហកម្មមានការកើនឡើងពី ១,៨ភាគរយ នៅឆ្នាំ ១៩៩៨ កើនដល់ ៧,២ភាគរយ នៅឆ្នាំ ២០១៩ និង វិស័យសេវាកម្មបានកើនឡើងពី ១១,៨ ភាគរយ នៅឆ្នាំ ១៩៩៨ កើនដល់ ១៦,២ ភាគរយ នៅឆ្នាំ ២០១៩។

## រូបភាព ២.១៤(ក) ការបែងចែកកម្លាំងពលកម្មជាភាគរយនៃអ្នកមានការងារធ្វើ តាមវិស័យសេដ្ឋកិច្ចខេត្តកំពង់ធំ




រូបភាព ២.១៤(ខ) បង្ហាញអំពីនិន្នាការនៃការបែងចែកភាគរយអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ចនៅក្នុងខេត្តសៀមរាបពីឆ្នាំ ១៩៩៨ ដល់ ២០១៩ ផ្អែកតាមលទ្ធផលជំរឿនប្រជាជនឆ្នាំ ១៩៩៨ ២០០៨ និង ២០១៩ កន្លងមក។ លទ្ធផលបានបង្ហាញថា ការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានការថយចុះពី ៨២,៥ ភាគរយ នៅឆ្នាំ ១៩៩៨ មកត្រឹម ៦១,៥ ភាគរយនៅឆ្នាំ ២០១៩ ខណៈដែលការចូលរួមកម្លាំងពលកម្ម នៅក្នុងវិស័យឧស្សាហកម្មមានការកើនឡើងពី ២,៤ ភាគរយ នៅឆ្នាំ ១៩៩៨ កើនដល់ ១០,៣ភាគរយ នៅឆ្នាំ ២០១៩ និង វិស័យសេវាកម្មបានកើនឡើងពី ១៥,១ ភាគរយនៅឆ្នាំ ១៩៩៨ កើនដល់ ២៨,២ ភាគរយ នៅឆ្នាំ ២០១៩។

រូបភាព ២.១៤(ខ) ការបែងចែកកម្លាំងពលកម្មជាភាគរយនៃអ្នកមានការងារធ្វើ
តាមវិស័យសេដ្ឋកិច្ចខេត្តសៀមរាប



## ២.២ ទីប្រជុំជន គ្រួសារ អាគារ និងលំនៅដ្ឋាន







### ២.២.១ ទីប្រជុំជន

ការកើនឡើងនូវនគរូបនីយកម្ម នៅលើពិភពលោកបានធ្វើឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ពិភពលោកនិងតាមប្រទេសនីមួយៗ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលតំបន់រដ្ឋបាលញឹកញាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន។ ការកែសម្រួលតំបន់រដ្ឋបាលនេះ ក៏ជាកត្តាមួយដែលធ្វើឲ្យមានការកើនឡើងនូវតំបន់ទីប្រជុំជន ដោយសារតំបន់មួយចំនួនក្លាយជាក្រុងជាគោលដៅអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែក និងលំនៅដ្ឋានទៀតផង។ ដូច្នេះផ្ទៃដីស្រែមួយចំនួនត្រូវបានបង្វែរមុខងារពីដីកសិកម្ម ទៅជាដីសម្រាប់ការសាងសង់នៅពេលអនាគត ។ កន្លងមកការកំណត់តំបន់ទីប្រជុំជនពុំមាននិយមន័យច្បាស់លាស់នៅឡើយទេ ។ នៅឆ្នាំ ១៩៩៨ ទីប្រឹក្សាជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ បានកំណត់ស្រុកដែលស្ថិតក្នុងទីរួមខេត្តជាទីប្រជុំជន ។ នៅឆ្នាំ ២០០៤ ជំនាញការរបស់មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ ២០០៤ បានកំណត់និយមន័យទីប្រជុំជនដោយកំណត់ ៣ លក្ខខណ្ឌគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅឆ្នាំ ២០១១ និយមន័យលក្ខខណ្ឌទីប្រជុំជនបានកែសម្រួលនៅលក្ខខណ្ឌទី ៣ គឺ ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ទៅជាភាគរយប្រជាជនទាំងពីរភេទធ្វើការនៅក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ហើយលក្ខខណ្ឌទី ១ និងទី ២ គឺរក្សានៅដដែល។ លក្ខខណ្ឌទាំងនោះគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយចំនួនប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅក្នុងរូបភាព ២.៩ បង្ហាញអំពីភាគរយចំនួនប្រជជានរស់នៅតំបន់ទីប្រជុំជន ដែលមាននិន្នាការកើនឡើងជាលំដាប់។ នៅក្នុងឆ្នាំ ១៩៩៨ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំផ្អែកលើការកំណត់ស្រុកក្នុងទីរួមខេត្តជាតំបន់ទីប្រជុំជនមានចំនួន ១៥,៧ភាគរយ ហើយនៅឆ្នាំ២០០៤ ការកំណត់និយមន័យទីប្រជុំថ្មីដោយប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ ១៩៩៨ ដដែលគឺមានការកើនចំនួន ២ ភាគរយ។ លទ្ធផលនៃការធ្វើជំរឿនៅឆ្នាំ ២០០៨ បានអនុវត្តន៍និយមន័យទីប្រជុំជនឆ្នាំ ២០០៤ គឺចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានចំនួន ១៩,៥ ភាគរយ និងផ្អែកលើនិយមន័យទីប្រជុំជនថ្មីឆ្នាំ ២០១១ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងដល់ ២៧,១ ភាគរយ ។ ភាគរយចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជននៅឆ្នាំ ២០១៨ តាមការប៉ាន់ស្មានមានចំនួន ៣៣,៦ ភាគរយ នឹងនៅឆ្នាំ ២០៣០ អាចកើនឡើងរហូតដល់ ៤៣ ភាគរយ ។ ទោះបីជានិយមន័យមានការខុសគ្នាយ៉ាងណាក៏ដោយ ជាក់ស្តែងប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើង ដោយសារកត្តាការកើនឡើងលំនៅដ្ឋានថ្មីៗ ការស្វែងរកការងារដែលពួកគាត់គិតថាមានលក្ខណៈប្រសើរជាងកន្លែងរស់នៅចាស់ និងកត្តាសេដ្ឋកិច្ចផ្សេងៗ។

### រូបភាព ២.១៥ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន




ប្រភព៖ ការកំណត់ចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញ ឆ្នាំ ២០១១

នៅក្នុងរូបភាព ១២.៦ បង្ហាញអំពីភាគរយនៃចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជន។ និន្នាការជារួមគឺមានការកើនឡើង ជាក់ស្តែងចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនបានកើនឡើងពី ១៨,៣ ភាគរយនៅឆ្នាំ ១៩៩៨ កើនដល់ ៣៩,៤ ភាគរយ នៅឆ្នាំ ២០១៩។ ខេត្តកំពង់ធំបានកើនឡើង២,២ ភាគរយនៅឆ្នាំ ១៩៩៨ កើនដល់ ១០,៣ភាគរយនៅឆ្នាំ ២០១៩ ខណៈដែលខេត្តសៀមរាប បានកើនឡើងចំនួន ១៧,២ ភាគរយ នៅឆ្នាំ ១៩៩៨ កើនដល់ ៣០,៦ភាគរយ នៅឆ្នាំ ២០១៩។ កត្តាសំខាន់ៗនៃការកើនឡើងនៃភាគរយចំនួនប្រជាជន ដោយសារកត្តាមួយចំនួនគឺ កំណើនប្រជាជន ការអភិវឌ្ឍន៍នគរូបនីយកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរតំបន់រដ្ឋបាល។

### រូបភាព ២.១៦ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន




ប្រភពៈ - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

## ២.២.២ គ្រួសារ និងអគារ

សូចនាករចំនួនគ្រួសារ គឺជាសូចនាករមួយមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការផ្តល់សេវាផ្សេងៗដូចជាអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ចំនួនគ្រួសារសរុបនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៦ លានគ្រួសារ ហើយបានកើនឡើងរហូតដល់ ៣,៣៤ លានគ្រួសារ នៅឆ្នាំ ២០១៩ សម្រាប់ទូទាំងប្រទេស។ ចំនួនអគារនៅទូទាំងប្រទេស ប្រហែលជិត ២ លានអគារនៅឆ្នាំ ១៩៩៨ និងបានកើនឡើងដល់ ៣ លានអគារ នៅឆ្នាំ ២០១៩។ ខេត្តកំពង់ធំនៅឆ្នាំ ១៩៩៨ មានចំនួនគ្រួសារ ១០៥.៥៨៣ ដែលមានចំនួនអគារប្រមាណ ៩៥.៤៥២ និងនៅឆ្នាំ ២០១៩ មានអគារប្រហែល ១៥៥, ១៨៣ អគារ បើគិតជាចំនួនអគារគិតជាមធ្យមមានប្រមាណ ៩៦ ភាគរយ នៃចំនួនគ្រួសារធៀបនឹងចំនួនគ្រួសារសរុប។ ខេត្តសៀមរាបនៅឆ្នាំ ១៩៩៨ មានចំនួនគ្រួសារ ១២៥.៣៨៧ ដែលមានចំនួនអគារប្រមាណ ១១៣.៣៥៦ និងនៅឆ្នាំ ២០១៩ មានអគារប្រហែល ២១៣, ០៧៦ អគារ បើគិតជាចំនួនអគារគិតជាមធ្យមមានប្រមាណ ៩៤,៨ ភាគរយធៀបនឹងចំនួនគ្រួសារសរុប ។

### តារាង ២.២ ចំនួនគ្រួសារ និង អគារ

| ឆ្នាំ | ចំនួនគ្រួសារ | | | ចំនួនអគារ | | |
|---|---|---|---|---|---|---|
| | ខេត្តកំពង់ធំ | ខេត្ត សៀមរាប | កម្ពុជា | ខេត្តកំពង់ធំ | ខេត្ត សៀមរាប | កម្ពុជា |
| 1998 | 105,583 | 125,387 | 2,162,086 | 95,452 | 113,356 | 1,954,634 |
| 2008 | 134,546 | 180,743 | 2,817,637 | 128,738 | 169,887 | 2,656,604 |
| 2019 | 160,766 | 224,672 | 3,341,770 | 155,183 | 213,076 | 3,304,066 |

### រូបភាព ២.១៧ ចំនួនគ្រួសារ និងអគារ




## ២.២.៣ លំនៅដ្ឋាន

នៅក្នុងប្រទេសកម្ពុជាមានចំនួនគ្រួសារសរុបប្រហែល ៣,៧ លានគ្រួសារ នៅក្នុងឆ្នាំ ២០២០ និងមានលំនៅដ្ឋានប្រមាណ ៣,៥ លាន ស្មើនឹង ៩៥ភាគរយ ខណៈដែលខេត្តកំពង់ធំមានចំនួនគ្រួសារប្រហែល ១៧៨ ពាន់គ្រួសារ និងមានលំនៅដ្ឋាន១៦៦ ពាន់លំនៅដ្ឋានស្មើនឹង ៩៣,២ ភាគរយ និងខេត្តសៀមរាបមានចំនួនគ្រួសារប្រហែល ២៤៦ ពាន់គ្រួសារ និងមានចំនួនលំនៅដ្ឋានប្រហែល ១៤៥ ពាន់លំនៅដ្ឋាន ស្មើនឹង ៩៩ភាគរយ។

## តារាង ២.៣ ចំនួនលំនៅដ្ឋានតាមប្រភេទ

| ប្រភេទលំនៅដ្ឋាន | កំពង់ធំ | សៀមរាប | កម្ពុជា |
|---|---|---|---|
| ចំនួនផ្ទះដំបូលប្រក់ស្លឹកស្បូវ | 6,585 | 4,457 | 50,268 |
| ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ | 57,362 | 132,333 | 1,759,171 |
| ចំនួនផ្ទះប្រក់ស័ង្កសីតិចជាង២០សន្លឹក | 4,388 | 10,971 | 140,856 |
| ចំ.ផ្ទះដំបូលប្រក់ក្បឿង | 87,961 | 70,858 | 1,094,012 |
| ចំ.ផ្ទះថ្មមិនមែនបេតុង | 6,863 | 20,505 | 239,357 |
| ចំ.ផ្ទះថ្មល្វែង | 2,152 | 5,077 | 204,637 |
| ចំ.ផ្ទះភូមិគ្រឹះ(វីឡា) | 292 | 1,087 | 17,592 |
| **សរុប** | **165,603** | **245,288** | **3,505,893** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៨, ២០១៩ និង ២០២០

## រូបភាព ២.១៨ ចំនួនលំនៅដ្ឋានឆ្នាំ ២០២០



## រូបភាព ២.១៩ ចំនួនលំនៅដ្ឋានតាម




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២០

## ២.៣ បរិស្ថាន ទឹកស្អាត និង បង្គន់អនាម័យ

### ២.៣.១ បរិស្ថាន



## ២.៣.១.១ តំបន់ការពារធម្មជាតិ និងព្រៃការពារ

នៅក្នុងប្រទេសកម្ពុជាមានព្រៃ ៥ ប្រភេទធំៗ ព្រៃជ្រុះស្លឹករួមទាំងព្រៃល្បោះ (១៨,៥%) ព្រៃស្រោង (១៥,៨%) ព្រៃពាក់កណ្តាលស្រោង (៥,៩%) ព្រៃលិចទឹក (២,៦%) និងព្រៃផ្សេងៗ (៥%) ដែលរាប់បញ្ចូលព្រៃដុះឡើងវិញ និងព្រៃលូតលាស់ឡើងវិញ ព្រៃកោងកាង កៅស៊ូ ចម្ការឈើ ចម្ការដូងប្រេង និងឬស្សី ខណៈដែល តំបន់មិនមានព្រៃមានប្រមាណ ៥២%។ នៅចន្លោះឆ្នាំ ២០០៦ ដល់ ២០១៨ ប្រទេសកម្ពុជាបាត់បង់ព្រៃឈើចំនួន ២,៧ លានហិកតា នៅក្នុងគ្រប់តំបន់អេកូឡូស៊ីទាំងអស់។ តំបន់មេគង្គខាងកើត និងតំបន់ទំនាបកណ្តាលបាត់បង់ព្រៃឈើក្នុងផ្ទៃដីធំជាងគេបំផុតចំនួន ៧៦០ ០០០ ហិកតា នៅក្នុងមួយតំបន់ ចំណែងកគម្របព្រៃឈើក្នុងតំបន់ប្រជុំភ្នំក្រវាញ ហាក់បីនៅមានចំនួនថេរ (ក្រសួងបរិស្ថានឆ្នាំ ២០១៨)។

**រូបភាព ២.២០ ប្រភេទព្រៃឈើ**




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១

## ២.៣.១.២ គម្របព្រៃឈើ

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលរក្សាបានគម្របព្រៃឈើមានចំនួនខ្ពស់ជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ តែទោះបីយ៉ាងណាក៏ដោយ និន្នាការនៃការប្រែប្រួលគម្របព្រៃឈើពីឆ្នាំ ១៩៦៥ មានចំនួនប្រហែល ៧៣% បានថយចុះមកត្រឹម ៤៧% នៅឆ្នាំ ២០១៨ ។

រូបភាព ២.២១ ការប្រែប្រួលគម្របព្រៃឈើ




សំគាល់៖ ព្រៃឈើទូទាំងប្រទេសរួមបញ្ចូលចម្ការកៅស៊ូ និងចម្ការដូងប្រេង។

ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ២.៣.១.៣ តំបន់ការពារ

តំបន់ការពារនៅក្នុងប្រទេសកម្ពុជាចែកជា៤ផ្នែកធំៗគឺ ១) ឧទ្យានជាតិ(National Park) មានផ្ទៃដី សរុប ៧៤២,៣ ពាន់ហិកតាស្មើនឹង ១៣,៨% ២) តំបន់ការពារសត្វព្រៃ (Wildlife Sanctuary) មានផ្ទៃដីចំនួន៤.១៣៧,៦ ពាន់ហិកតា ស្មើនឹង ៧៦,៩% ៣) តំបន់ប្រាសាទ (Protected Land Scape) មានចំនួន ៩៧ ពាន់ហិកតា ស្មើនឹង ១,៨% និងតំបន់គ្រប់គ្រងប្រើប្រាស់ច្រើនយ៉ាង(Multiple Use Management) មានចំនួន ៤០៣,៩ ពាន់ហិកតា ស្មើនឹង ៧,៥%។

## រូបភាព ២.២២ តំបន់ការពារ




ប្រភព÷ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។*

## ២.៣.១.៤ តំបន់វាលភក់ និងលក្ខណៈពិសេស

តំបន់វាលភក់មាននៅតាមដងទន្លេដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង និងតំបន់ដែលមានបឹងធំៗ ជាដើម ដែលមានចំនួន ១៧ គឺ បឹងព្រីង ប្រព័ន្ធទន្លេក្រចេះ ប្រព័ន្ធទន្លេស្រែពក ប្រព័ន្ធទន្លេសេសាន ព្រៃលិចទឹក ទន្លេមេគង្គស្ទឹងត្រែង ប្រព័ន្ធទន្លេមេគង្គពាមជីលាំង បឹងប្រាសាទទុយោ បឹងវាលសំណាប់ បឹងប្រាំង បឹងចាំងរុង ប្រព័ន្ធសុងសែនខាងលើ ភូមិមុតពាម បឹងវាលដំរី ស្ទឹងសែនទាប បឹងធ្នារ និង បឹងវាលពក ។

## រូបភាព ២.២៣ តំបន់វាលភក់ គិតជាហិកតា




ប្រភព÷ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។*

## ២.៣.១.៥ គ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន

ផ្អែកលើទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២០ បានបង្ហាញថា គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សមានចំនួន ៥១.០៤៦ គ្រួសារ ស្មើនឹង ១,៤ ភាគរយ ធៀបនឹងចំនួនគ្រួសារសរុប ខណៈដែលខេត្តកំពង់ធំមានចំនួន ២,២២៨ គ្រួសារ ស្មើនឹង ១,៣ ភាគរយ និងខេត្តសៀមរាបមានចំនួន ៣០.៥៨៨ គ្រួសារ ស្មើនឹង ១២,៥ ភាគរយ ធៀបនឹងចំនួនគ្រួសារសរុប នៅក្នុងខេត្តនីមួយៗ។ ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះ នៅទូទាំងប្រទេសមានចំនួន ៤៤៨ ០៥៥ គ្រួសារ ស្មើនឹង ១២,២ភាគរយ ធៀបទៅនឹងគ្រួសារសរុប ហើយខេត្តកំពង់ធំមានចំនួនគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះមានចំនួន ២.៩១១ គ្រួសារ ស្មើនឹង ១,៦ភាគរយ និងខេត្តសៀមរាបមានចំនួន ២៤.៧២៧ គ្រួសារ ស្មើនឹង ០,៧ភាគរយ ធៀបទៅនឹងចំនួនគ្រួសារសរុបរបស់ខេត្តនីមួយៗ។ ចំនួនគ្រួសារ ដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាននៅទូទាំងប្រទេសមានចំនួន ៤១.៨៨១គ្រួសារ ស្មើនឹង១,១ភាគរយធៀបនឹងគ្រួសារសរុប ខណៈដែលខេត្តកំពង់ធំមានចំនួន ១,៦៥១ ស្មើនឹង ០,៩ភាគរយ និងខេត្តសៀមរាបមានចំនួន១.៧៦៤ គ្រួសារ ស្មើនឹង ០,៧ភាគរយ ធៀបនឹងចំនួនគ្រួសារសរុបក្នុងខេត្តនីមួយៗ។

### តារាង ២.៤ ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ ២០២០

| អធិប្បាយ | ខេត្តកំពង់ធំ | ខេត្តសៀមរាប | កម្ពុជា |
|---|---|---|---|
| គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 2,228 | 30,588 | 51,046 |
| គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 2,911 | 24,727 | 448,055 |
| គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 1,651 | 1,764 | 41,881 |
| **ចំនួនគ្រួសារសរុប** | 177,728 | 245,507 | 3,677,585 |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២០

នៅក្នុងរូបភាព ២.២៤ បង្ហាញថា គ្រួសារដែលមានសេវាសំរាមតាមផ្ទះមានតែ ១២,២ភាគរយ ប៉ុណ្ណោះដែលទទួលបានសេវានេះ ហើយចំនួនគ្រួសារចំនួន ៨៧,៨ ភាគរយទៀតពុំទាន់បានទទួលសេវាប្រមូលសំរាម ។ នៅក្នុងកំពង់ធំ ចំនួនគ្រួសារដែលទទួលបានសេវាប្រមូលសំរាមមានតែ ១,៦ ភាគរយ តិចជាងទូទាំងប្រទេស ខណៈដែលខេត្តសៀមរាបមានចំនួនគ្រួសារដែលបានទទួលសំរាមមានចំនួន ១០,១ ភាគរយ តិចជាងទូទាំងប្រទេសជាង ២,១ ភាគរយ។

### រូបភាព ២.២៤ ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ ២០២០




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២០

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៣ឆ្នាំ ២០១៩ បាន បង្ហាញថា ការផ្តល់សេវាប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងនៅទីប្រជុំជន ក្រុង ស្រុក ភាគច្រើនអនុវត្តដោយអ្នកគ្រប់គ្រងផ្សារ ឬ ភាស៊ីផ្សារដែលមានរហូតដល់ ៥៣ ភាគរយ ហើយការផ្តល់សេវានេះដោយក្រុមហ៊ុនឯកជននៅទីប្រជុំជន ក្រុងមានចំនួនតែ ២០ ភាគរយ ប៉ុណ្ណោះ ។ មូលហេតុមកពីនៅតាមទីប្រជុំជនស្រុក ការចូលរួមបង់ថ្លៃសេវាកម្មដឹកជញ្ជូនសំរាម សំណល់រឹងមានតែអាជីវករលក់ដូរតាមតូបក្នុងផ្សារ និងហាងទំនិញ ឬ ផ្ទះប្រជាពលរដ្ឋជុំវិញផ្សារតែប៉ុណ្ណោះ ហើយដែលក្រុមហ៊ុនពិបាកនឹងទទួលយក ( ទំហំការងារមិនសមាមាត្រនឹងចំណាយរបស់ក្រុមហ៊ុន ) ហើយយោងតាមរូបភាព ២.១៥ បង្ហាញថា ២៤ភាគរយ ទៀតពុំទទួលបានសេវាប្រមូលសំរាម សំណល់រឹង ទីប្រជុំជននៅក្នុងក្រុង សំណល់រឹងទូទាំងប្រទេស។

**រូបភាព ២.២៥ ភាគរយការផ្តល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស ឆ្នាំ ២០១៧**




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

នៅក្នុងរូបភាព ២.២៦ បង្ហាញពីបរិមាណសំណល់រឹងទីប្រជុំជន ដែលចាក់នៅទីលានប្រចាំឆ្នាំ ពី២០០៤ ដល់ឆ្នាំ ២០១៧ (ក្រសួងបរិស្ថាន ២០១៧ច) ។ ជាមួយនឹងកំណើនសន្សឹមៗចាប់ពី ៣១៧.៥៥០ តោន នៅឆ្នាំ ២០០៤ រហូតដល់ប្រមាណជាង ៦៣៥.០០០ តោន ក្នុងឆ្នាំ ២០១១ និង មានសន្ទុះខ្លាំងនៅឆ្នាំ បន្ទាប់គឺប្រមាណជាង ៩៣០.០០០តោន ។ ទិន្នន័យឆ្នាំ ២០១៧ បង្ហាញថា សំណល់រឹងដែលបានចាក់នៅទីលានសរុបមានប្រមាណ ១.៤៥៤.៦៥៣ តោន ធៀបនឹងឆ្នាំ ២០១៦ គឺកើនឡើង ១៨៨.០៣៣តោន ស្មើនឹង ១៤,៨ ភាគរយ និងមានកំណើន ៤៦,៩ភាគរយ ធៀបនឹងឆ្នាំ ២០១៣។

### រូបភាព ២.២៦ បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំ




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

នៅក្នុង ២.២៧ បង្ហាញអំពីបរិមាណសំណល់រឹងប៉ាន់ប្រមាណនៅឆ្នាំ ២០១៥ នៅទូទាំងប្រទេសមានចំនួន ៤.០៩០.២០៩ តោន/ឆ្នាំ ដែលក្នុងបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ២.៥៧១.២៣៥ តោន/ឆ្នាំ ស្មើនឹង ៦៣ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ១.១៩៤.៤៥៦ តោន/ឆ្នាំ ស្មើនឹង ២៩ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៣២៤.៥១២ តោន/ឆ្នាំ ស្មើនឹង ៨ភាគរយ ។ ខេត្តកំពង់ធំ បរិមាណសំណល់រឹងប៉ាន់ប្រមាណ ២២៣.៣០០ តោន/ឆ្នាំ ដែលក្នុងបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន១១៥.៧០៥ តោន/ឆ្នាំ ស្មើនឹង ៥២ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ៧៤.០៩៥ តោន/ឆ្នាំ ស្មើនឹង ៣៣ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៣៣.៥៨០ តោន/ឆ្នាំ

ស្មើនឹង ១៥ ភាគរយ ។ ខេត្តសៀមរាប បរិមាណសំណល់រឹងប៉ាន់ប្រមាណ៥២៧.៨១១ តោន/ឆ្នាំ ដែលក្នុងបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ៣១៩.៧៤០ តោន/ឆ្នាំ ស្មើនឹង ៦១ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ១៩៤.៩១០ តោន/ឆ្នាំ ស្មើនឹង ៣៧ ភាគរយ និងបរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ១៣.១៦១ តោន/ឆ្នាំ ស្មើនឹង ២ ភាគរយ ។

### រូបភាព ២.២៧ បរិមាណសំណល់រឹងទីក្រុងឆ្នាំ ២០១៥




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ២.៣.២ ទឹកស្អាត និងទឹកកខ្វក់















ទឹកបានដើរតួនាទីយ៉ាងសំខាន់ជាគ្រឹះសម្រាប់ការអភិវឌ្ឍនានានៃប្រទេសមួយ។ ប្រទេសកម្ពុជាពិតជាមានចំណងជាក់លាក់ខ្លាំងទៅនឹងអ្វីដែលត្រូវបានហៅ មាសខៀវ ដូចដែលវាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយ ដែលអំណោយទានដ៏ពិសិដ្ឋ ជាពិសេសធនធានទឹក។ ភ្នំគូលែននៃអតីតចក្រភពខ្មែរ មានភាពល្បីល្បាញដោយសារទឹកដ៏ពិសិដ្ឋ ហើយរាជធានីអង្គរវត្ត ក៏បានបង្ហាញពីប្រព័ន្ធធារាសាស្ត្រដ៏ទំនើបបំផុតនៃសម័យនោះផងដែរ។ ប្រជាជនកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងទៅលើទឹកសាបជាជាងតំបន់ឆ្នេរសមុទ្រ ជាពិសេសជលផលទឹកសាប សម្រាប់ទ្រទ្រង់ដល់ជីវភាពរស់នៅ និងសម្រាប់ជាប្រភពប្រូតេអ៊ីនចម្បងរបស់ពួកគេ។ ប្រទេសកម្ពុជាទទួលរងនូវអាកាសធាតុត្រូពិចដែលនាំឱ្យមានការឆ្លាស់គ្នានៃរដូវខ្វះទឹក និងរដូវទឹកច្រើនហួស។ ប្រភពទឹកសាបសំខាន់ៗរបស់ប្រទេសកម្ពុជាមានដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់ ស្ទឹង ព្រែក ទឹកបឹង ទឹកត្រពាំង ទឹកចេញពីក្រោមដី និងទឹកភ្លៀងជាដើម។ ទន្លេមេគង្គ និងទន្លេសាបមានសារៈសំខាន់សម្រាប់ប្រព័ន្ធជលសាស្ត្រកម្ពុជា ហើយ វាជាប្រភពដ៏សំខាន់សម្រាប់ការផ្គត់ផ្គង់ប្រូតេអ៊ីននៅកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានផ្លាស់ប្តូរ ខណៈពេលដែលចំនួនប្រជាជនកំពុងតែកើនឡើង ហើយតម្រូវការទឹកកំពុងកើនឡើងជាមួយនឹងកង្វះការការពារ ដែលប្រកបដោយប្រសិទ្ធភាព។ កំណើនសេដ្ឋកិច្ចបាននាំឱ្យមានតម្រូវការទឹកខ្លាំងសម្រាប់វិស័យឧស្សាហកម្ម និងកសិកម្ម ដែលធ្វើឱ្យមានការប្រកួតប្រជែងរវាងវិស័យទាំងនេះជាមួយនឹងវិស័យផ្សេងទៀត ហើយវាកំពុងតែធ្វើឱ្យមានការប៉ះពាល់ទាំងបរិមាណ និងគុណភាពទឹក។

គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី ៦ មានចំណុចដៅចំនួន ៨ និងសូចនាករចំនួន ១១ ដែលនឹងត្រូវប្រើ ដើម្បីជម្រុញសកម្មភាពឆ្ពោះទៅរកការទទួលបានជាសកលនូវការគ្រប់គ្រងទឹកស្អាត និង អនាម័យដោយសុវត្ថិភាព និងការគ្រប់គ្រងធនធានទឹកសមស្រប។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ ទទួលស្គាល់ការគ្រប់គ្រងទឹកប្រកបដោយចីរភាព សំដៅលើការផ្គត់ផ្គង់ទឹកស្អាត (ចំណុចដៅ ៦.១) និង អនាម័យ (ចំណុចដៅ ៦.២) ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន។ គោលដៅនេះ ក៏ផ្តោតលើបញ្ហាដូចជា គុណភាពទឹក និងការគ្រប់គ្រងសំណល់រាវ (ចំណុចដៅ ៦.៣) កង្វះខាតទឹក និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព (ចំណុចដៅ ៦.៤) ការគ្រប់គ្រងធនធានទឹក (ចំណុចដៅ ៦.៥) និងការការពារ និងការស្តារប្រព័ន្ធអេកូឡូស៊ីទាក់ទងនឹងទឹក (ចំណុចដៅ ៦.៦)។

## ក.ទឹកស្អាត

នៅឆ្នាំ២០១៩ ភាគរយទីតាំងប្រភពទឹកសម្រាប់ទទួលទាននៅទូទាំងប្រទេសមានចំនួនគ្រួសារ ៦៤ ភាគរយ មានទឹកនៅក្នុងលំនៅដ្ឋាន ខណៈដែលខេត្តកំពង់ធំមានចំនួន ៦២ភាគរយ និង ខេត្តសៀមរាបមានចំនួន ៦២ ភាគរយស្មើនឹងខេត្តកំពង់ធំ ។ សម្រាប់ការទៅយកទឹកមកទទួលទានដែលមានចម្ងាយតិចជាង ៣០នាទី នៅទូទាំងប្រទេសមានចំនួនគ្រួសារ ២៤ ភាគរយ ខេត្តកំពង់ធំមានចំនួន ២៨ភាគរយ និងខេត្តសៀមរាបស្មើនឹងទូទាំងប្រទេស ២៤ ភាគរយ។ ការទៅយកទឹកមកទទួលទានដែលមានចម្ងាយច្រើនជាង ៣០នាទី នៅទូទាំងប្រទេសមានចំនួនគ្រួសារចំនួន ៧ ភាគរយ ខេត្តកំពង់ធំចំនួន ៥ភាគរយ និងខេត្តសៀមរាបចំនួន ៦ ភាគរយ ខណៈដែលមិនដឹងពីចម្ងាយសម្រាប់ទូទាំងប្រទេស និងខេត្តកំពង់ធំមានភាគរយគ្រួសារចំនួនស្មើគ្នាគឺ ៥ភាគរយ និងខេត្តសៀមរាប ៦ ភាគរយ។

### រូបភាព ២.២៧ ភាគរយគ្រួសារ តាមទីតាំងប្រភពទឹកទទួលទាន ឆ្នាំ ២០១៩




ប្រភព៖ លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

នៅក្នុងប្រទេសកម្ពុជាភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ ១៩៩៨ មានចំនួន ២៩ ភាគរយ ហើយបានកើនឡើងរហូតដល់ ៧៣ ភាគរយនៅឆ្នាំ ២០១៩ ផ្អែកតាមទិន្នន័យជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ។ នៅក្នុងរវាង១០ឆ្នាំ បើប្រៀបធៀបរវាងឆ្នាំ ១៩៩៨ និង ២០០៨ ភាគរយនៃការប្រើប្រាស់ទឹកស្អាតបានកើនឡើងមានចំនួន ១៨ ភាគរយ និងពីឆ្នាំ ២០០៨ ដល់ ២០១៩ កើនឡើង ២៦ ភាគរយ ។ ខេត្តកំពង់ធំភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ

១៩៩៨ មានចំនួន ៤ភាគរយ បានកើនឡើងដល់ ៥៧ ភាគរយ នៅឆ្នាំ ២០១៩ ខណៈដែលខេត្តសៀមរាប នៅឆ្នាំ ១៩៩៨ មាន ១៣,៤ ភាគរយ បានកើនឡើងដល់ ៧១ ភាគរយ នៅឆ្នាំ ២០១៩។

**រូបភាព ២.២៨ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់**




*សំគាល់៖ ទឹកស្អាតសម្រាប់ទទួលទានរួមមានទឹកបំពង់បណ្តាញក្នុងលំនៅដ្ឋាន ទឹកបំពង់បណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន ទឹកបំពង់សាធារណៈ អណ្តូងស្នប់/អណ្តូងខួង អណ្តូងជីកមានគម្របការពារ ទឹកភ្លៀង និងទឹកដប/ទឹកពិសារដេប។*

ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ខ.ទឹកកខ្វក់

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ ២០១៩ បង្ហាញថា បរិមាណសំណល់រាវបញ្ចេញចោលនៅរាជធានីភ្នំពេញក្នុងឆ្នាំ ២០១៣ មានប្រមាណ១០៨.១៩៨.៧២៥ ម$^{៣}$/ឆ្នាំ គឺមានការកើនឡើងប្រមាណ ១៧.៨៩៨.៥៧៤ ម$^{៣}$/ឆ្នាំ បើប្រៀបធៀបឆ្នាំ ២០១២។ មានន័យថា ឆ្នាំ ២០១២ បរិមាណសំណល់រាវដែលបញ្ចេញចោលនៅរាជធានីភ្នំពេញ មាន ៩០.២៩៩.២៣៤ម$^{៣}$/ឆ្នាំ។ បរិមាណបញ្ចេញចោលនេះ មានការកើនឡើងជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំ ។ រូបភាព ២.១៩ បង្ហាញពីបរិមាណទឹកកខ្វក់នៅរាជធានីភ្នំពេញ ដែលបានបញ្ចេញចោលនៅក្នុងចន្លោះឆ្នាំ ២០០៦ ដល់ ២០១៧។

រូបភាព ២.២៩ បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ ឆ្នាំ ២០០៦ ដល់ ២០១៧




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

## ២.៣.៣ បង្គន់អនាម័យ

នៅក្នុងឆ្នាំ ១៩៩៨ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ១២,៨ ភាគរយ បានកើ ៣៣,៧ ភាគរយ នៅឆ្នាំ ២០០៨ និងនៅឆ្នាំ ២០១៩ កើនឡើងដល់ ៨៣,៨ ភាគរយ ។ ខេត្តកំពង់ធំភាគរយគ្រួសារមានបង្គន់ប្រើប្រាស់មានចំនួន ១៣ ភាគរយ នៅឆ្នាំ ១៩៩៨ បានកើនឡើងដល់ ៨១ ភាគរយ នៅឆ្នាំ ២០១៩ ខណៈដែលខេត្តសៀមភាគរយគ្រួសារមានបង្គន់ប្រើប្រាស់នៅឆ្នាំ ១៩៩៨ មានចំនួន ៧ ភាគរយ បានកើនឡើងដល់ ៧៩ ភាគរយ នៅឆ្នាំ ២០១៩។

## រូបភាព ២.៣០ ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ២.៤ គ្រោះមហន្តរាយ


ចំណុចដៅ ១៣.១
ពង្រឹងសមត្ថភាពធន់ និងភាពបន្សាំទៅ
នឹងគ្រោះធម្មជាតិពាក់ព័ន្ធ
នឹងគ្រោះមហន្តរាយ
អាកាសធាតុ
ចំណុចដៅ ១៣.២
ធ្វើសមាហរណកម្មការរាស់វែង
ការប្រែប្រួលអាកាសធាតុ
ទៅក្នុងគោលនយោបាយ
និងផែនការជាតិ
ចំណុចដៅ ១៣.៣
លើកកម្ពស់ការយល់ដឹង និងសមត្ថភាព
ដើម្បីឆ្លើយតបនឹងការប្រែប្រួល
អាកាសធាតុ
ចំណុចដៅ ១៣.A
UNFCCC
អនុវត្តអនុសញ្ញានៃក្របខណ្ឌ
សហប្រជាជាតិស្តីពី
ការអាកាសធាតុ
ចំណុចដៅ ១៣.B
ជំរុញយន្តការលើកកម្ពស់សមត្ថភាព
សម្រាប់ឱ្យបង្កើតផែនការ
និងការគ្រប់គ្រងបញ្ហា
អាកាសធាតុ
13 CLIMATE ACTION

គ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ គ្រោះរាំងស្ងួត ការបាក់ច្រាំងទន្លេស្ទឹង ការបាក់រលំអគារ ឬ សំណង់ អគ្គីភ័យ ការពុលស្រា និងជំងឺឆ្លងផ្សេងៗ ។ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយដែលប៉ះពាល់ដល់ប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ដែលជានិច្ចកាលគ្រោះថ្នាក់ទាំងនេះរមែងនាំឱ្យមានការចំណាយខ្ពស់ជាងគេផងដែរ។ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី ១៣ វិធានការចំពោះអាកាសធាតុមានគោលបំណងចាត់វិធានការជាបន្ទាន់ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយអភិវឌ្ឍសមត្ថភាពរបស់ប្រទេសនីមួយៗ ដើម្បីកាត់បន្ថយហានិភ័យអាកាសធាតុ និងការបន្សាំ។ គ្រោះមហន្តរាយមាននៅក្នុងចំណុចដៅ ៣.១ នៅក្នុងគោលដៅទី ១៣ នៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ២.៤.១ គ្រោះមហន្តរាយធម្មជាតិ

គ្រោះមហន្តរាយធម្មជាតិ សំដៅលើគ្រោះថ្នាក់ធម្មជាតិ ដែលបានកើតឡើង ដូចជា ខ្យល់ព្យុះ រន្ទះបាញ់ គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ជាដើម។

រូបភាព ២.៣១ បង្ហាញអំពីចំនួនអ្នកស្លាប់ដោយសារអគ្គីភ័យនៅទូទាំង ប្រទេសសរុបមានចំនួន ១០នាក់ សរុបរយៈពេល ៥ ខែ ឆ្នាំ ២០២១ ទាបជាងឆ្នាំ ២០២០ មានចំនួន ២២នាក់ ខណៈដែលចំនួនអ្នកស្លាប់ដោយខ្យល់កន្ត្រាក់មានចំនួន ៣ នាក់ តិចជាង ឆ្នាំ ២០២០ មានចំនួន ៥ នាក់ និង អ្នកស្លាប់ដោយសាររន្ទះបាញ់មានចំនួន ៤៥ នាក់ទាបជាងឆ្នាំ ២០២០ មានចំនួន ៦២ នាក់។ តែទោះបីយ៉ាងណាក៏ ការស្លាប់ដោយរន្ទះបាញ់មានចំនួនច្រើនគួរឲ្យមានក្តីបារម្ភ និងគួរមានវិធានការណ៍សមស្របណាមួយដើម្បីកាត់បន្ថយអ្នកស្លាប់ដោយសាររន្ទះបាញ់នេះ។ នៅក្នុង នៅក្នុងរយៈពេល ៥ខែ ឆ្នាំ ២០២១ ខេត្តសៀមរាប និងខេត្តកំពង់ធំពុំមានអ្នកស្លាប់ដោយសារអគ្គីភ័យ និង ខ្យល់កន្ត្រាក់ទេ តែខេត្តកំពង់ធំមានអ្នកស្លាប់ដោយសារគ្រោះថ្នាក់រន្ទះចំនួន ៥នាក់ ខណៈដែលខេត្តសៀមរាបពុំមានអ្នកស្លាប់។

**រូបភាព ២.៣១ ចំនួនអ្នកស្លាប់ដោយគ្រោះមហន្តរាយនៅទូទាំងប្រទេស**




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ ២០២១

*សំគាល់: គិតត្រឹមរយៈពេល ៥ខែ ឆ្នាំ ២០២១។*

រូបភាព ២.៣២ បង្ហាញអំពីចំនួនអ្នកស្លាប់ដោយគ្រោះធម្មជាតិ ដោយផ្អែកលើទិន្នន័យមូលដ្ឋានឆ្នាំ ២០១៨, ២០១៩ និង ឆ្នាំ ២០២០។ ចំនួនអ្នកស្លាប់ដោយសារគ្រោះទឹកជំនន់មានចំនួន ២៣៤ នាក់ មានចំនួនច្រើនជាងគេ ខណៈដែលគ្រោះថ្នាក់ខ្យល់ព្យុះមានចំនួន ៥៣នាក់ និង រន្ទះបាញ់មានចំនួន ១២៤ នាក់ ។ ខេត្តកំពង់ធំចំនួនអ្នកស្លាប់ដោយខ្យល់ព្យុះមានចំនួន ៥នាក់ រន្ទះបាញ់ចំនួន១៣នាក់ និងគ្រោះទឹកជំនន់មានចំនួន ២៥ នាក់ ខណៈដែលខេត្តសៀមរាបចំនួនអ្នកស្លាប់ដោយគ្រោះទឹកជំនន់មានចំនួន ២២នាក់ច្រើនជាងគ្រោះថ្នាក់ដោយខ្យល់ព្យុះ និងគ្រោះថ្នាក់រន្ទះបាញ់។

**រូបភាព ២.៣២ ចំនួនអ្នកស្លាប់ដោយគ្រោះធម្មជាតិ**




ប្រភព÷ ទិន្នន័យមូលដ្ឋានឆ្នាំ ២០១៨, ២០១៩ និង ២០២០

រូបភាព ២.៣៣ បង្ហាញអំពីចំនួនគ្រួសារ ដែលរងគ្រោះដោយសារខ្យល់ព្យុះ គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត ដោយផ្អែកលើទិន្នន័យមូលដ្ឋាន ឆ្នាំ ២០១៨, ២០១៩ និង ២០២០។ ចំនួនគ្រួសារដែលទទួលរងគ្រោះដោយគ្រោះរាំងស្ងួតមានចំនួន ១១១.០២០ គ្រួសារ ច្រើនជាងគេគ្រោះថ្នាក់គ្រោះទឹកជំនន់មានចំនួន ១០៣.៩៥៨គ្រួសារ និង ខ្យល់ព្យុះ។ ខេត្តកំពង់ធំចំនួនគ្រួសាររងគ្រោះដោយសារគ្រោះរាំងស្ងួតមានចំនួន ៨,២៧៦ គ្រួសារច្រើនជាង គ្រោះផ្សេងទៀត ខណៈដែលខេត្តសៀមរាប ក៏មាននិន្នាការដូចគ្នានេះដែរ។

### រូបភាព ២.៣៣ ចំនួនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ




ប្រភព÷ ទិន្នន័យមូលដ្ឋានឆ្នាំ ២០១៨, ២០១៩ និង ២០២០

## ២.៤.២.គ្រោះអគ្គីភ័យ

គ្រោះថ្នាក់ដោយសារអគ្គីភ័យមិនបានរាប់បញ្ចូលនៅក្នុងគ្រោះថ្នាក់ធម្មជាតិទេ អាចនិយាយថាជាឧបទហេតុ ដែលកើតឡើងដោយការឆ្លងចរន្តអគ្គិសនី ឬ ដោយសារការធ្វេសប្រហែសអ្វីមួយ ខុសពីប្រទេសដទៃដែលអាចកើតឡើងដោយភ្លើងឆេះព្រៃជាដើម។

រូបភាព ២.៣២ បង្ហាញអំពីការបាត់បង់ និងការខូចខាតដោយអគ្គីភ័យ រយៈពេល៥ ខែ ឆ្នាំ ២០២១ ដែលបានកើតឡើងចំនួន ២៣៤លើក និងធ្វើឲ្យខូចខាតផ្ទះសម្បែង សម្ភារៈផ្សេងៗ និងគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សផងដែរ។ ទិន្នន័យលម្អិតមាននៅក្នុងក្រាហ្វិកខាងក្រោម។

## រូបភាព ២.៣២ ការបាត់បង់ និង ខូចខាតដោយអគ្គិភ័យ




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ ២០២១

*សំគាល់: គិតត្រឹមរយៈពេល ៥ខែ ឆ្នាំ ២០២១។*

រូបភាព ២.៣៣ បង្ហាញអំពីគ្រោះមហន្តរាយ ដោយសារខ្យល់កន្ត្រាក់គិតត្រឹមរយៈពេល ៥ ខែ ឆ្នាំ ២០២១ នៅទូទាំងប្រទេសដែលបានកើតឡើងចំនួន ១១០ លើក និងធ្វើខូចខាត និងបាត់បង់ ខូចខាតផ្ទះសម្បែង និងប៉ះពាល់ដល់អាយុជីវិតមនុស្សទៀតផង។

## រូបភាព ២.៣៣ ខ្យល់កន្ត្រាក់




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ ២០២១

*សំគាល់: គិតត្រឹមរយៈពេល ៥ខែ ឆ្នាំ ២០២១។*

### ២.៤.៣.ជំងឺឆ្លង

នៅក្នុងសម័យថ្មីនេះ ជំងឺឆ្លងត្រូវបានគេចាត់ទុកជាគ្រោះមហន្តរាយមួយផងដែរ ដូចជា ជំងឺគ្រុនឈាម គ្រុនឈឹក និងជំងឺកូវីដ១៩ ដែលកំពុងរាតត្បាតពាសពេញពិភពលោក ហើយប្រទេសប្រទេសកម្ពុជាក៏មានអ្នកស្លាប់ ២.៩៤៩ នាក់ គិតត្រឹមថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១ ខណៈដែលនៅលើពិភពលោកមានអ្នកស្លាប់ជាង ៥ លាននាក់។ នៅឆ្នាំ ២០២០ ជំងឺគ្រុនឈាមនៅទូទាំងប្រទេសមានចំនួន ៩០០៨ ករណី និងគ្រុនឈឹក មានចំនួន ៥៩៩៨ ករណី និងចំនួនអ្នកឆ្លងជំងឺកូវីដ ១៩ មានចំនួន ១២០.១៨៣ នាក់ គិតត្រឹមថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១។

**រូបភាព ២.៣៤ ចំនួនករណីជំងឺឆ្លងនៅប្រទេសកម្ពុជា**




ប្រភព÷ - របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ ២០២០ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (ជំងឺគ្រុនឈាម និងជំងឺគ្រុនឈឹក)

- ប្រព័ន្ធតាមដានករណីឆ្លងជំងឺកូវីដ ១៩ គិតត្រឹមថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១ (https://covid19-map.cdcmoh.gov.kh)។

### រូបភាព ២.៣៤ ចំនួនករណីជំងឺឆ្លងកូវីដ ១៩ ទូទាំងពិភពលោក (គិតត្រឹមថ្ងៃទី ២ ខែ ធ្នូឆ្នាំ ២០២១)




ប្រភព÷ គេហទំព័រ Worldometer គិតត្រឹមថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១ (https://www.worldometers.info/coronavirus/?utm_campaign=homeAdUOA?Si )។

### រូបភាព ២.៣៥ ចំនួនករណីជំងឺឆ្លងកូវីដ ១៩ នៅកម្ពុជា (គិតត្រឹមថ្ងៃទី ២ ខែ ធ្នូឆ្នាំ ២០២១)




ប្រភព÷ - ប្រព័ន្ធតាមដានករណីឆ្លងជំងឺកូវីដ ១៩ គិតត្រឹមថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១ (https://covid19-map.cdcmoh.gov.kh)។

## ២.៥ ការប្រែប្រួលអាកាសធាតុ












នៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ បានកំណត់គោលដៅចំនួន ១៧ ដែលក្នុងនោះ នៅក្នុងគោលដៅទី ១៣ គឺ វិធានការលើការប្រែប្រួលអាកាសធាតុ (Climate Action) ។ នៅក្នុងគោលដៅទី ១៣ នេះ មានចំណុចដៅចំនួន ៥ គឺ ១៣.១, ១៣.២, ១៣.៣, ១៣.A និង ១៣.B ។

ការប្រែប្រួលអាកាសធាតុ គឺជាដំណើរការប្រែប្រួលបន្តិចម្តងៗនៃអាកាសធាតុ ក្នុងរយៈពេលវែង ក្នុងនោះរួមមាន សីតុណ្ហភាព និង ស្ថានភាពទឹកភ្លៀង របបខ្យល់ ឬ គម្របទឹកកក ជាដើម។ ការប្រែប្រួលនេះ កើតឡើងដោយសារ កត្តាធម្មជាតិ និងសកម្មភាពមនុស្សផងដែរ។ មូលហេតុ នៃការប្រែប្រួលអាកាសធាតុ អាចកើតឡើងដោយធម្មជាតិ ឬដោយសារសកម្មភាពមនុស្សរួមមាន៖

- សកម្មភាពមនុស្ស ដូចជាការដុតប្រេងឥន្ធនៈហ្វូស៊ីល ការកាប់បំផ្លាញព្រៃឈើ កសិកម្ម ។ល។ បានបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន ទៅក្នុងបរិយាកាសផែនដី
- កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសរាំងស្កាត់កំដៅដែលផ្លាតចេញពីផ្ទៃផែនដី ឱ្យនៅក្នុងបរិយាកាសកាន់តែច្រើន ដែលជាមូលហេតុនៃកំណើនកំដៅសកល
- បាតុភូត “ផលផ្ទះកញ្ចក់” សំដៅលើកំណើនសីតុណ្ហភាពបរិយាកាស ដោយសារកំដៅដែលចាំងផ្លាតពីផ្ទៃផែនដី ហើយត្រូវរាំងស្កាត់មិនឱ្យភាយចេញទៅ ក្នុងលំហអវកាសបាន
- ឧស្ម័នផ្ទះកញ្ចក់(GHGs)សំខាន់ៗ នៅក្នុងបរិយាកាសរួមមាន ៖ ចំហាយទឹក(water vapor), ឧស្ម័នកាបូនិច $CO_2$, មេតាន $CH_4$, ឌីអាសូតម៉ូណូអុកស៊ីត $N_2O$, អ៊ីដ្រូហ្លុយអរ៉ូកាបូន HFCs, ពែរហ្លុយអរ៉ូកាបូន PFCs, ស៊ុលភួអិចសាក្លរូ $SF_6$ ។

ការប្រែប្រួលអាកាសធាតុបានធ្វើឲ្យមានគ្រោះធម្មជាតិផ្សេងៗដូចជាខ្យល់ព្យុះ គ្រោះទឹកជំនន់ និងភាពរាំងស្ងួតជាដើម។ គ្រោះធម្មជាតិទាំងនេះ បានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅខ្លាំងចំពោះប្រជាជននៅតាមជនបទជាពិសេសប៉ះពាល់ដល់ការធ្វើកសិកម្ម។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការនៃការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងឆ្នាំ ១៩៩៥ ។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគនិរតីនៃឧបទ្វីបអាស៊ីបូព៌ា ហើយផ្ទៃដីប្រមាណ ២០ ភាគរយត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិកម្ម ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកទាំងស្រុង និងស្ថិតនៅចំណុចខាងត្បូងច្រើនជាង ១០ អង្សានៅលើអេក្វាទ័រ។ សីតុណ្ហភាពអតិបរមាខ្ពស់ជាង ៣៣ អង្សាសេ ជាទូទៅចាប់ផ្តើមរដូវវស្សានៅខែមីនា និងខែមេសា ហើយអាចកើនឡើងដល់ ៣៨ អង្សាសេ។ សីតុណ្ហភាពអប្បបរមាធ្លាក់នៅក្រោម ១០ អង្សាសេ ។ នៅ ខែមករាជាខែត្រជាក់បំផុត និង ខែមេសាជាខែដែលក្តៅបំផុត។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំគឺរវាង ១៤២ និង ២០០ សង់ទីម៉ែត្រ ។ ភ្លៀងធ្លាក់ពីខែ មេសាដល់ខែកញ្ញាក្នុងតំបន់ដីទំនាបបឹងទន្លេសាប មេគង្គ ជាមធ្យមប្រចាំឆ្នាំពី ១១០ ទៅ ១៩០ សង់ទីម៉ែត្រ ប៉ុន្តែបរិមាណនេះប្រែប្រួលដែលគួរឲ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ តែទោះបីយ៉ាងណាក៏ដោយ តំបន់ទឹកភ្លៀងដ៏ធំបំផុតនេះភាគច្រើនហូរទៅសមុទ្រ

ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ដែលហូរតាមស្ទឹងទន្លេចូលក្នុងបឹងទន្លេសាប។ សំណើមនៅប្រទេសកម្ពុជា គឺខ្ពស់នៅពេលយប់ពេញមួយឆ្នាំ និងនៅពេលរដូវប្រាំងសំណើមមធ្យមប្រមាណ ៥០ ភាគរយ ឬ ទាបជាងបន្តិច ប៉ុន្តែវាអាចមានប្រមាណ ៦០ ភាគរយ នៅរដូវវស្សា។

## ២.៥.១ ស្ថានភាពទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០១៧ មានធ្លាក់ចុះមក ពី ១.៥៨៣,៦ មីលីម៉ែត្រនៅឆ្នាំ ២០២១០ មកត្រឹម ១.៥០៦ មីលីម៉ែត្រនៅឆ្នាំ ២០១៧ ខណៈដែលនៅឆ្នាំ ២០១១ និងឆ្នាំ ២០១៣ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១,៧៦៧មីលីម៉ែត្រ ទៅ ១,៧៨១ មីលីម៉ែត្រ និងនៅក្នុងឆ្នាំ ២០១២ និងឆ្នាំ ២០១៤ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១.៦៣២ មីលីម៉ែត្រទៅ១.៦៦០ មីលីម៉ែត្រ។ ចំពោះស្ថានភាពទឹកភ្លៀងក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ មានចំនួនទឹកភ្លៀងតិចជាងទូទាំងប្រទេស លើកលែងតែនៅឆ្នាំ ២០១៤ ខេត្តកំពង់ធំមានចំនួនទឹកភ្លៀងខ្ពស់ប្រហែល ៦.០០០ មីលីម៉ែត្រ។

**រូបភាព ២.៣៦ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយ៍គិតជាមីលីម៉ែត្រ**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

និន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យម បើពិនិត្យជារួមសម្រាប់នៅទូទាំងប្រទេសមានការថយចុះ ហើយនិន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់នៅក្នុងខេត្តបាត់ដំបង និងសៀមរាបមានស្ថានភាពដូចនៅទូទាំងប្រទេសដែរ ប៉ុន្តែខេត្តបន្ទាយមានជ័យមាននិន្នាការកើនឡើងខុសពីស្ថានភាពនៅទូទាំងប្រទេស និងខេត្តទាំងពីរខាងលើ។ និន្នាការចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យមនៅទូទាំងប្រទេសមានការកើនឡើងនៅក្នុងឆ្នាំ ២០១១ និង ២០១២ ហើយបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០១៥ ខណៈដែលខេត្តបាត់ដំបងបានកើនឡើងបន្តិចនៅឆ្នាំ ២០១៣ ហើយបានធ្លាក់ចុះនៅឆ្នាំ ២០១៤ និងនៅឆ្នាំ ២០១៥ រក្សាស្ថានភាពដដែល និងខេត្តសៀមរាបបានថយចុះនៅឆ្នាំ ២០១៣ ហើយបានកើនឡើងនៅឆ្នាំ ២០១៤ និងបានធ្លាក់ចុះនៅឆ្នាំ ២០១៥។ ចំណែកឯខេត្តបន្ទាយមានជ័យបានកើនឡើងខ្ពស់នៅឆ្នាំ ២០១១ និង ២០១២ និងបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០១៣ ហើយបានកើនឡើងចាប់ពីឆ្នាំ ២០១៤។

**រូបភាព ២.៣៧ ចំនួនថ្ងៃមានភ្លៀងក្នុងឆ្នាំគិតជាមធ្យមតាមស្ថានីយ៍**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

### ២.៥.២ សីតុណ្ហភាព

រូបភាព ២.៣៨ បង្ហាញអំពី សីតុណ្ហភាពអប្បបរមានៅក្នុងខេត្តកំពង់ធំ ខេត្តសៀមរាប និងទូទាំងប្រទេស មាននិន្នាការថយចុះដូចគ្នា។ សីតុណ្ហភាពអប្បបរមាគឺបានថយចុះពីកម្រិតលើ ២០ អង្សាសេ នៅឆ្នាំ ២០១១ មកជិត ១៥ អង្សាសេនៅ ឆ្នាំ ២០២១ ទាំងទូទាំងប្រទេស ខេត្តកំពង់ធំ និងខេត្តសៀមរាបគឺមាននិន្នការប្រហាក់ប្រហែលគ្នា។ នៅក្នុងឆ្នាំ ២០១៦ និង ២០១៨ សីតុណ្ហភាពអប្បបរមានៅក្នុងខេត្តសៀមរាប បានធ្លាក់ចុះក្រោម ១៥ អង្សាសេ ខណៈដែល សីតុណ្ហភាពអប្បបរមានៅក្នុងខេត្តកំពង់ធំ និងទូទាំងប្រទេសនៅត្រឹម ១៥ អង្សាសេ នោឆ្នាំ ២០១៦ និង លើ ១៥ អង្សាសេនៅឆ្នាំ ២០១៨។

**រូបភាព ២.៣៨ សីតុណ្ហភាព អប្បបរមា គិតជាអង្សាសេ**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

រូបភាព ២.៣៩ បង្ហាញអំពី សីតុណ្ហភាពអតិបរមានៅក្នុងខេត្តកំពង់ធំ ខេត្តសៀមរាប និង ទូទាំងប្រទេស មាននិន្នាការកើនឡើងដូចគ្នា។ សីតុណ្ហភាពអតិបរមា បានកើនឡើងលើសពី ៣០ អង្សាសេ នៅឆ្នាំ ២០១១ កើនឡើងដល់ជិត ៤០អង្សាសេ នៅឆ្នាំ ២០២១ ទាំងទូទាំងប្រទេស ខេត្តកំពង់ធំ និងខេត្តសៀមរាប ខណៈដែលនៅឆ្នាំ ២០១៦ សីតុណ្ហភាពអតិបរមាបានកើនឡើងខ្ពស់ជាង ៤០ អង្សាសេ។

**រូបភាព ២.៣៩ សីតុណ្ហភាព អតិបរមា គិតជាអង្សាសេ**




សំគាល់៖ សីតុណ្ហភាពឆ្នាំ ២០២១ គិតត្រឹមខែ កញ្ញា ឆ្នាំ ២០២១

ប្រភពៈ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ២.៥.៣ កម្ពស់ទឹក

នៅក្នុងរូបភាព ២.៤០ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកនៅទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ ២០១១ ដល់ ២០២០តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់មាននិន្នាការថយចុះ។ កម្ពស់ទឹកទន្លេមេគង្គអតិបរមានៅក្នុងឆ្នាំ ២០១១ មានកម្ពស់ជិត១៨ ម៉ែត្រ បានធ្លាក់មកក្រោម ១០ម៉ែត្រ នៅឆ្នាំ ២០២០ ខណៈដែលកម្ពស់ទឹកអប្បបរមា នៅឆ្នាំ ២០១១ មានកម្ពស់ប្រហែល ២.៥ ម៉ែត្របានថយមកត្រឹមជិត ២ម៉ែត្រនៅឆ្នាំ ២០២០ ។

### រូបភាព ២.៤០ កម្ពស់ទឹក នៅទន្លេមេគង្គ គិតជាម៉ែត្រ




ប្រភពៈ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

នៅក្នុងរូបភាព ២.៤១ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកអតិបរមាទន្លេមេគង្គគិតជាម៉ែត្រ ពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០២០។ និន្នាការនៃកម្ពស់ទឹកបានបង្ហាញថា កម្ពស់ទឹកទន្លេមគង្គអតិបរមានៅឆ្នាំ ១៩៩០ មានកម្ពស់ជិត ១៨ ម៉ែត្រ ហើយបានធ្លាក់ចុះប្រហែលពាក់កណ្តាលក្រោម ៨ ម៉ែត្រនៅឆ្នាំ ២០២០ ក្នុងរយៈពេល ៣០ ឆ្នាំ នេះ។ កម្ពស់ទឹក អប្បបរមាក៏មានការធ្លាក់ចុះប្រហែល ០,៥ ម៉ែត្រ ពីឆ្នាំ ២០១១ ដល់ ឆ្នាំ ២០២០។ នៅពេលអនាគត ប្រសិនបើកម្ពស់ទឹកអតិបរមាកាន់តែថយចុះនោះ នឹងមានផលប៉ះពាល់យ៉ាងខ្លាំង ដល់ការផ្គត់ផ្គង់ទឹកនៅក្នុងការធ្វើប្រើប្រាស់ទឹកសម្រាប់ការដាំដំណាំកសិកម្មមច្ឆាជាតិ និងជីវចម្រុះផ្សេងៗទៀតផងដែរ។ ដូច្នេះ សន្តិសុខស្បៀង នឹងមានផលប៉ះពាល់ ព្រោះទឹកទន្លេមេគង្គជាប្រភពទឹកមួយសម្រាប់ចែកចាយទៅដៃទន្លេផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រូបភាព ២.៤១ កម្ពស់ទឹកជាអតិបរមានៅទន្លេមេគង្គ គិតជាម៉ែត្រ




រូបភាព ២.៤២ កម្ពស់ទឹកជាអប្បបរមានៅទន្លេមេគង្គ គិតជាម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

# ជំពូក ៣
# ការវិភាគលទ្ធផល

## ៣.១ ព័ត៌មានទូទៅ
### ៣.១.១ គ្រួសារ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងនៅក្នុងខេត្តកំពង់ធំ និង ខេត្តសៀមរាប សម្រាប់តំបន់ខ្ពង់រាប ។ តារាងបញ្ជីសំណួរ ២ ត្រូវបានប្រើប្រាស់មានតារាងបញ្ជីសំណួរសម្រាប់សួរទៅមេភូមិនូវព័ត៌មាននៅក្នុងភូមិទាំងមូល និងតារាងបញ្ជីសំណួរសម្រាប់សួរមេគ្រួសារ គឺសម្ភាសន៍មេគ្រួសារផ្ទាល់។ ចំនួនគ្រួសារដែលត្រូវសម្ភាសន៍មានចំនួន ៤៨០ គ្រួសារ ក្នុងចំណោមគ្រួសារសរុប ២.៨៥០ គ្រួសារ ដោយផ្អែកលើចំនួនថវិកាដែលមានកម្រិត។ មេគ្រួសារដែលបានសម្ភាសន៍ គឺបុរសមានចំនួន ៣៦២ នាក់ ស្មើនឹង ៧៥,៤% និង ស្ត្រីជាមេគ្រួសារមានចំនួន ១១៨ នាក់ ស្មើនឹង ២៤,៦ ភាគរយ ក្នុងចំណោម ៤៨០ គ្រួសារ។

**តារាង ៣.១ ចំនួនគ្រួសារដែលត្រូវសម្ភាសន៍**

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កំពង់ធំ | ស្រុកស្ទឹងសែន | ស្រយ៉ូវ | ពុកពុយ | 540 | 60 |
| | | | អាចារ្យលាក់ | ក្រចាប់ | 739 | 60 |
| | | កំពង់ស្វាយ | ត្រពាំងឬស្សី | ថ្នល់បំបែក <ក> | 258 | 60 |
| | | | ត្បែង | បាគង | 279 | 60 |
| ២ | សៀមរាប | អង្គរធំ | លាងដៃ | បំពេញរាជ្យ | 223 | 60 |
| | | | ពាក់ស្នែង | ដប់សោម | 171 | 60 |
| | | បន្ទាយស្រី | ព្រះដាក់ | តាកុះ | 431 | 60 |
| | | | ខ្នាសណ្តាយ | ប្រី | 209 | 60 |
| សរុប | | | | | 2,850 | 480 |

**តារាង ៣.២ ចំនួនគ្រួសារដែលត្រូវសម្ភាសន៍**

| មេគ្រួសារ | សរុប | ភាគរយ |
|---|---|---|
| ប្រុស | 362 | 75.4 |
| ស្រី | 118 | 24.6 |
| សរុប | 480 | 100.0 |

តារាង ៣.៣ បង្ហាញតួលេខចំនួនគ្រួសារបែងចែកតាមក្រុមអាយុក្នុងចំណោមមេគ្រួសារទាំង ៩០០ នាក់ ដែលបានចុះសម្ភាសន៍ផ្ទាល់នៅក្នុងភូមិគោលដៅ ។ តាមតួលេខ ចំនួនតួលេខមេគ្រួសារក្រុមអាយុពី៤០ ដល់ ៥៩ ឆ្នាំ មានចំនួន ២១៥ នាក់ (៤៥%) មេគ្រួសារស្ថិតក្នុងក្រុមអាយុ ១៥ ដល់ ៣៩ ឆ្នាំ មានចំនួន ១៨៩ នាក់ (៣៩%) និង មេគ្រួសារស្ថិតក្នុងក្រុមអាយុ ៦០ឆ្នាំ ឡើងមានចំនួន ៧៨នាក់ (១៦%) បើប្រៀបធៀបទៅនឹងចំនួនមេគ្រួសារសរុប។ មេគ្រួសារភាគច្រើនជាបុរសមានចំនួន ៣៦២ នាក់ (៧៥%) និង មេគ្រួសារជាស្ត្រីមានចំនួន ១១៨ នាក់ (២៥%)។

**តារាង ៣.៣ ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ**

| ក្រុមអាយុ | ភេទមេគ្រួសារ | | |
|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ |
| **១៥ ដល់ ៣៩ឆ្នាំ** | 152 | 35 | 187 |
| **៤០ ដល់ ៥៩ឆ្នាំ** | 158 | 57 | 215 |
| **៦០ឆ្នាំ ឡើង** | 52 | 26 | 78 |
| **សរុប** | 362 | 118 | **480** |

## ៣.១.២ ទំហំគ្រួសារ

រូបភាព ៣.៤ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមលទ្ធផលចុងក្រោយ ជំរឿនទូទៅប្រជាជនឆ្នាំ ១៩៩៨ ឆ្នាំ ២០០៨ និង ឆ្នាំ ២០១៩ មាននិន្នាការជារួមធ្លាក់ចុះសម្រាប់ខេត្ត២ និងទូទាំងប្រទេសពីជាង ៥នាក់ក្នុងមួយគ្រួសារមកជាង ៤នាក់ក្នុងមួយគ្រួសារ។ ការធ្លាក់ចុះនេះអាចបណ្ដាលមកពីអត្រាកំណើតធ្លាក់ចុះ ទាំងនៅថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ ដែលផ្អែកលើការយល់ដឹងអំពីគោលនយោបាយផែនការគ្រួសារ។

### រូបភាព ៣.៤ បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ ១៩៩៨, ២០០៨ និង ឆ្នាំ ២០១៩




ប្រភព៖ លទ្ធផលចុងក្រោយ នៃជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ ១៩៩៨ ឆ្នាំ២០០៨ និង ឆ្នាំ ២០១៩

រូបភាព ៣.៥ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមការចុះសម្ភាសន៍ផ្ទាល់ជាមួយនឹងមេគ្រួសារ ៤៨០ នាក់ ក្នុងនោះខេត្តសៀមរាបមានចំនួនមេគ្រួសារ ២៤១នាក់ និង ខេត្តកំពង់ធំមានចំនួនមេគ្រួសារ ២៣៩ នាក់ ។ ជាលទ្ធផលបញ្ជាក់ថា ចំនួនសមាជិកគ្រួសារជាមធ្យមសរុបនៃខេត្តទាំង ២ មានចំនួន ៤,៧ នាក់ ក្នុងមួយគ្រួសារ ខ្ពស់ជាងលទ្ធផលជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ ចំនួន ០,៤ នាក់។ ខេត្តកំពង់ធំមានចំនួនសមាជិកគ្រួសារជាមធ្យម ៤,៩ នាក់ ខ្ពស់ជាងលទ្ធផលជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ ចំនួន ០,៧ នាក់ និង ខេត្តសៀមរាបមានចំនួនសមាជិកគ្រួសារជាមធ្យម ៤,៦ នាក់ ខ្ពស់ជាង លទ្ធផលជំរឿនទូទៅប្រជាជនឆ្នាំ ២០១៩ ចំនួន ០,២ នាក់ ។ រូបភាព ៣.៥ ខាងក្រោម បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យម។

រូបភាព ៣.៥ បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ ២០២១ (ការសម្ភាសន៍ជាក់ស្តែង)




## ៣.១.៣ ចំណាកស្រុក

ទិន្នន័យនៅក្នុង តារាង ៣ ៤ បង្ហាញថា ចំនួនប្រជាជន ១២១ នាក់ ស្មើនឹង ៥,៣ ភាគរយ នៅក្នុងចំណោមប្រជាជន ២.២៧៣ នាក់ ដែលបានធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស។ នៅក្នុងចំណោមប្រជាជន ១២១នាក់ ដែលបានធ្វើចំណាកស្រុកនោះ មានចំនួនប្រជាជន ១១២នាក់បានធ្វើចំណាកស្រុកក្នុងប្រទេសស្មនឹង ៩៣ភាគរយ ធៀបជាមួយនឹងចំនួនប្រជាជនចំណាកស្រុកសរុប និង ស្មើនឹង ៤,៩ភាគរយ ធៀបនឹងចំនួនប្រជាជនសរុប និង ចំនួនប្រជាជនដែលបានធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ៩ នាក់ ស្មនឹង ៧ ភាគរយ ធៀបនឹងចំនួនប្រជាជនចំណាកស្រុកសរុប និង ស្មើនឹង ០,៤ភាគរយ ធៀបនឹងចំនួនចំនួនប្រជាជនសរុប។

តារាង ៣.៤ ចំនួនសមាជិកអចិន្ត្រៃយ៍ និង សមាជិកចំណាកស្រុក

| អធិប្បាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| **សមាជិកអចិន្ត្រៃយ៍** | 1,112 | 1,161 | 2,273 |
| **សមាជិកចំណាកស្រុក** | 64 | 57 | 121 |
| សមាជិកចំណាកស្រុកក្នុងប្រទេស | 58 | 54 | 112 |
| សមាជិកចំណាកស្រុកក្រៅប្រទេស | 6 | 3 | 9 |

រូបភាព ៣.៦ បង្ហាញថា ភាគរយសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកក្នុងប្រទេសភេទប្រុសមានចំនួន ៩១ ភាគរយ ខណៈដែលការធ្វើចំណាកស្រុកទៅក្រៅប្រទេសមានតែ ៩ ភាគរយ ។ ចំណែកឯសមាជិកគ្រួសារភេទស្រី ដែលបានធ្វើចំណាកស្រុកនៅក្នុងប្រទេសមានចំនួនច្រើនជាងសមាជិកគ្រួសារភេទប្រុសមានចំនួន ៩៥ភាគរយ និងធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ៥ ភាគរយតិចជាងបុរស។

**រូបភាព ៣.៦ ភាគរយសមាជិកគ្រួសារធ្វើចំណាកស្រុកចែកតាមភេទ**






## ក.ចំណាកស្រុកក្នុងប្រទេស

ការធ្វើចំណាកស្រុកសំដៅការផ្លាស់ប្តូរទីលំនៅដ្ឋានពីភូមិមួយទៅភូមិមួយទៀត បើទោះបីនៅក្នុងខេត្តតែមួយក៏ដោយ។ ទិន្នន័យក្នុងរូបភាព ៣.៥ បានបង្ហាញថា រាជធានីខេត្តដែលមានសមាជិកគ្រួសារបានធ្វើ ចំណាកស្រុកពីខេត្តសៀមរាប និងខេត្តកំពង់ធំ ចូលទៅក្នុង ២៥ រាជធានីខេត្តក្នុងព្រះរាជាចក្រកម្ពុជា ក្នុងនោះក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាបក៏មានចំនួនប្រជាជនផ្លាស់ពីស្រុកមួយទៅស្រុកមួយក្នុងខេត្តទាំង២នេះ ផងដែរ។ រាជធានីភ្នំពេញមានចំនួនភាគរយខ្ពស់ជាងគេ បន្ទាប់មកខេត្ត សៀមរាប និងខេត្តដែលមានចំនួនតិចបំផុត គឺកំពង់ឆ្នាំង និងខេត្តកោះកុង។ រីឯខេត្តដែលមិនបានរៀបរាប់គឺពុំមានសមាជិកគ្រួសារធ្វើចំណាកស្រុកនោះទេ។

**រូបភាព ៣.៥ ចំនួនសមាជិកគ្រួសារបានធ្វើចំណាកស្រុកតាមបណ្តាខេត្ត**




### ក១.មូលហេតុនៃចំណាកស្រុកក្នុងប្រទេស

រូបភាព ៣.៦ បង្ហាញអំពីមូលហេតុដែលសមាជិកនៅក្នុងគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទិន្នន័យនេះ បានបង្ហាញថា ចំនួនសមាជិកបានធ្វើចំណាកស្រុក ដោយសារតែការស្វែងរកការងារធ្វើមានចំនួនច្រើនជាងគេមានចំនួន ៨៧នាក់ (៧៧,៧%) ស្វែងរកការងារធ្វើមានចំនួន ១១នាក់ (៨,៩%) និង មូលហេតុផ្សេងៗមានចំនួន ៤ នាក់ (៣,៦%) ក្នុងចំណោមមូលហេតុនៃការចំណាកស្រុកក្នុងប្រទេស ។

រូបភាព ៣.៦ ភាគរយសមាជិកចំណាកស្រុកក្នុងប្រទេសតាមមូលហេតុ




## ខ.ចំណាកស្រុកក្រៅប្រទេស

រូបភាព ៣.៧ បង្ហាញថា ចំនួនសមាជិកដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃមានចំនួន ៥ នាក់ (៥៦%) ក្នុងចំណោមចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសសរុប ៩ នាក់ ហើយបន្ទាប់មក ប្រទេសកូរ៉េខាងត្បូង មានចំនួន ២នាក់ (២២%) និង ប្រទេសជប៉ុន ២នាក់ (២%) ។

រូបភាព ៣.៦ ចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសតាមប្រទេស



## ខ១.មូលហេតុនៃចំណាកស្រុកទៅក្រៅប្រទេស

រូបភាព ៣.៧ បង្ហាញថាចំនួនសមាជិកបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយសារ ដោយសារតែស្វែងរកការងារធ្វើមានចំនួនសរុប ៧ នាក់ (៨៥%) និង ប្តូរទីកន្លែងធ្វើការមានចំនួន២ នាក់ (២២%)។ ក្នុងចំណោមអ្នកធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើមានបុរសចំនួន ៥នាក់ ស្មើនឹង ៧១ភាគរយ និង ស្ត្រីមានចំនួន ២ នាក់ ស្មើនឹង ២៩ភាគរយ ធៀបនឹងចំនួនអ្នកធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើសរុប។ ចំណែកអ្នកធ្វើចំណាកស្រុកដោយមូលហេតុប្តូរទីកន្លែងការងារមានចំនួន ១នាក់ ទាំងបុរស និងស្ត្រី ។

រូបភាព ៣.៧ មូលហេតុនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស




### ៣.១.៤ ការចូលរួមកម្លាំងពលកម្ម

#### ក. វិស័យសេដ្ឋកិច្ច

តារាង ៣.៥ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មរបស់សមាជិកគ្រួសារទៅតាមវិស័យសេដ្ឋកិច្ចនៅខេត្តគោលដៅនីមួយៗ សរុបមានចំនួន ១.០៧២ នាក់ ស្មើនឹង ៤៧,២% ក្នុងចំណោមប្រជាជនសរុប ២.២៧៣នាក់ ។ ក្នុងនោះអ្នកធ្វើការកសិកម្មមានចំនួនច្រើនជាងគេមានចំនួន ៦៦៩ នាក់ ស្មើនឹង ៦២,៤% ដែលក្នុងនោះផ្នែកនេសាទមានចំនួន ១៩នាក់ ស្មើនឹង ១,៨% និងដាំដំណាំ និងធ្វើស្រែចំនួន ៦៥០នាក់ ស្មើនឹង ៦០,៦% ។ អ្នកធ្វើការក្នុងវិស័យឧស្សាហកម្មមានចំនួន ៤៥នាក់ ស្មើនឹង ៤,១ % និងវិស័យសេវាកម្មមានចំនួន ៣៥៨នាក់ ស្មើនឹង ៣៣,៤% ។

តារាង ៣.៥ ចំនួនសមាជិកធ្វើការតាមវិស័យសេដ្ឋកិច្ច

| តាមវិស័យសេដ្ឋកិច្ច | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ដាំដំណាំ | 351 | 299 | 650 |
| នេសាទ | 18 | 1 | 19 |
| ឧស្សាហកម្ម | 20 | 25 | 45 |
| សេវាកម្ម | 213 | 145 | 358 |
| សរុប | 602 | 470 | 1,072 |

រូបភាព ៣.៨ ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច




## គ. ផ្នែកការងារ

តារាង ៣.៥ បង្ហាញពីចំនួនសមាជិកគ្រួសារដែលបានចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ។ ទិន្នន័យនេះ ឃើញថាសមាជិកភាគច្រើន បានចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឯកជនមានចំនួន ៥៩១នាក់ ស្មើនឹង ៥៥ ភាគរយ ក្នុងនោះផ្នែកឯកជនខ្មែរមានចំនួន ៥៥៦នាក់ ស្មើនឹង ៥២ភាគរយ និងផ្នែកឯកជនបរទេសមានចំនួន ៣៥នាក់ ស្មើនឹង ៣ ភាគរយ ។ សមាជិកគ្រួសារដែលធ្វើការសម្រាប់គ្រួសារមានចំនួន ៣៧៩នាក់ (៣៥%) ខណៈដែលសមាជិកធ្វើការក្នុងផ្នែករដ្ឋាភិបាលមានចំនួន ១០៣ នាក់ ស្មើនឹង ១០ ភាគរយ។

### តារាង ៣.៦ ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ

| ផ្នែកការងារ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| រាជរដ្ឋាភិបាល | 60 | 42 | 103 |
| ផ្នែកឯកជនខ្មែរ | 313 | 243 | 556 |
| ផ្នែកឯកជនបរទេស | 18 | 16 | 35 |
| ផ្នែកគ្រួសារ | 222 | 157 | 379 |
| **សរុប** | **614** | **459** | **1,072** |

### រូបភាព ៣.៩ ភាគរយសមាជិកគ្រួសារធ្វើការតាមផ្នែកនៃការងារ




## ៣.២ បរិស្ថាន
### ៣.២.១ បង្គន់អនាម័យ

រូបភាព ៣.១០ បង្ហាញអំពីភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យប្រើប្រាស់ឆ្នាំ ២០២១ តាមរយៈការធ្វើសម្ភាសន៍ផ្ទាល់គឺមានគ្រួសារ ប្រហែល ៩៥ ភាគរយមានបង្គន់អនាម័យប្រើប្រាស់ នៅសល់តែ ៥ភាគរយ ប៉ុណ្ណោះដែលគ្មានបង្គន់ប្រើប្រាស់ ។

រូបភាព ៣.១០ ភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ




### ៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីការចាក់សំរាម

រូបភាព ៣.១១ បង្ហាញអំពីចំនួនគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម ។ តាមទិន្នន័យនេះបង្ហាញថា ទិន្នន័យជារួមនៅក្នុងឆ្នាំ២០២១ នៅតាមតំបន់គោលដៅដែលបានចុះសម្ភាសន៍គឺមានគ្រួសារប្រហែលក្រោម ១ ភាគរយ មានសេវាប្រមូលសំរាមនៅតាមគេហដ្ឋាន ខណៈដែលទីតាំងប្រមូលសំរាមមានជាង ៥ភាគរយបន្តិច និង ទីតាំងទុកសំរាមនៅបរិវេណគេហដ្ឋានមានចំនួនប្រហែល ៨៧ ភាគរយ។

## រូបភាព ៣.១១ ភាគរយគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម




### ៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត

រូបភាព ៣.១២ បង្ហាញឲ្យឃើញថា ភាគរយគ្រួសារផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត។ទិន្នន័យនេះ បង្ហាញថា គ្រួសារទទួលរងផលប៉ះពាល់ដោយសារការបាញ់ថ្នាំសម្លាប់សត្វល្អិត មានចំនួនប្រហែល ៣៣ ភាគរយ ផលប៉ះពាល់ដោយសារការប្រើថ្នាំគីមីមានចំនួន ១៨ ភាគរយ ផលប៉ះពាល់ដោយសារការចាក់សំរាមតាមទីសាធារណៈ មានចំនួនប្រហែល ៥ភាគរយ និង ផលប៉ះពាល់ដោយសារការបង្ហូរទឹកសំអុយមានចំនួនប្រហែលក្រោម ១ ភាគរយ ដែលមានបង្ហាញនៅក្នុងរូបភាពខាងក្រោម។

រូបភាព ៣.១២ ភាគរយគ្រួសារទទួលរងផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត។




## ៣.៣ គ្រោះមហន្តរាយ

គ្រោះមហន្តរាយគឺសំដៅទៅលើគ្រោះមហន្តរាយកើតឡើងដោយធម្មជាតិមានដូចជា ខ្យល់ព្យុះ រន្ទះបាញ់ ទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងទន្លេ ឬ ស្ទឹង ព្រៃកជាដើម។ នៅក្នុងចំណោមគ្រួសារ ៤៨០ ដែលបានសម្ភាសន៍ មានចំនួន៤៥៤ គ្រួសារ ស្មើនឹង ៩៥ភាគរយ ឆ្លើយថាទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ និង គ្រួសារចំនួន ២៦ ស្មើនឹង ៥ ភាគរយ ឆ្លើយថាពុំទទួលរងគ្រោះដោយសារគ្រោះមហន្តរាយខាងលើ។ រូបភាព ១៣ បង្ហាញអំពីភាគរយគ្រួសារដែលទទួលរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិនៅឆ្នាំ ២០២១ ។

**រូបភាព ៣.១៣ ភាគរយគ្រួសារដែលទទួលគ្រោះមហន្តរាយនៅឆ្នាំ ២០២១ ក្នុងភូមិគោលដៅ**




រូបភាព ៣.១៤បង្ហាញថា ព័ត៌មានដែលគ្រួសារទទួលបានតាមរយៈទូរស័ព្ទដៃមានចំនួន ២៦៥ គ្រួសារ (៥៦%) ច្រើនជាងគេ បន្ទាប់មកតាមរយៈអាជ្ញាធរមូលដ្ឋានមានចំនួន ២៥១ គ្រួសារ (៥២%) តារយៈការផ្សាយទូរទស្សន៍ មានចំនួន ២៣៧ គ្រួសារ (៤៩ %) តាមរយៈ វិទ្យុ មានចំនួន ១៣៣ គ្រួសារ (២៨%) និងទទួលបានតាមប្រភពផ្សេងៗមានចំនួន ៦៦ គ្រួសារ (១៤%) តិចជាងគេ ក្នុងចំណោមគ្រួសារចំនួន ៤៨០ ដោយសួរសំណួរដាច់ដោយឡែកនៃប្រភពព័ត៌មាន។

**រូបភាព ៣.១៤ ភាគរយគ្រួសារដែលទទួលបានប្រភពព័ត៌មាននៃគ្រោះមហន្តរាយ**



តារាង ៣.៦ និង រូបភាព ៣.១៥ បង្ហាញថា ចំនួនគ្រួសារទទួលរងគ្រោះដោយសារខ្យល់ព្យុះមានចំនួន ៤៥៤គ្រួសារ ស្មើនឹង ៨៥ភាគរយ ច្រើនជាងគេ បន្ទាប់មកគ្រោះរាំងស្ងួតមានចំនួន ១៨៩ គ្រួសារ ស្មើនឹង ៣៩ ភាគរយ និង ទឹកជំនន់មានចំនួន ៥៨ គ្រួសារ ស្មើនឹង ១២ភាគរយ ខណៈដែលរន្ទះបាញ់ មិនមានកើតឡើងសម្រាប់គ្រួសារដែលបានសម្ភាសន៍នោះទេ។

**តារាង ៣.៧ ចំនួនគ្រួសារទទួលរងគ្រោះតាមប្រភេទគ្រោះមហន្តរាយ**

| ប្រភេទគ្រោះមហន្តរាយ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ខ្យល់ព្យុះ | 454 | 94.5 |
| ទឹកជំនន់ | 58 | 12.1 |
| រាំងស្ងួត | 189 | 39.4 |

**រូបភាព ៣.១៥ ភាគរយគ្រួសារទទួលរងគ្រោះមហន្តរាយតាមប្រភេទគ្រោះមហន្តរាយ**



## ៣.៤ ការប្រែប្រួលអាកាសធាតុ

### ៣.៤.១ ស្ថានភាពទឹកភ្លៀង

រូបភាព ៣.១៧ បង្ហាញឲ្យឃើញថា ស្ថានភាពភ្លៀងធ្លាក់តាមការចំណាំរបស់ប្រជាជនដែលបានផ្តល់ចម្លើយអំឡុងពេលសម្ភាសន៍គឺ មានចំនួនមេគ្រួសារ ៣៦៤ នាក់ (៧៦%) បានឆ្លើយថា មានភ្លៀងមិនទៀងទាត់ ហើយមានចំនួនមេគ្រួសារ ៨៩ នាក់ (១៨%) ឆ្លើយថាភ្លៀងទៀងទាត់ខ្លះ និង មិនទៀងទាត់ខ្លះ ខណៈចំនួនមេគ្រួសារឆ្លើយថាភ្លៀងធ្លាក់ទៀងទាត់ខ្លះ២៧នាក់ (៦%) ប៉ុណ្ណោះ ។




### ៣.៤.២ ស្ថានភាពសីតុណ្ហភាព

តារាង ៣.៧ និង រូបភាព ៣.១៧ បង្ហាញថាចំនួនមេគ្រួសារ ៣៩៦ នាក់ (៨២,៥%) បានឆ្លើយថា សីតុណ្ហភាពមានកម្តៅខ្លាំង ខណៈដែលចំនួនមេគ្រួសារ៦៤ នាក់ (១៣,៣%) ឆ្លើយថា សីតុណ្ហភាពមានកម្តៅល្មមអាចទ្រាំទ្របាន និង ចំនួនមេគ្រួសារ ២០នាក់(៤,១%) ឆ្លើយថា ត្រជាក់ខ្លាំង និង ត្រជាក់ល្មម ក្នុងគ្រួសារដែលឆ្លើយថាត្រជាក់ខ្លាំងមានចំនួន ១៥នាក់ (៣,១%) និង ត្រជាក់ល្មម មានចំនួន ៥នាក់ (១%) ។

## តារាង ៣.៧ ចំនួនមេគ្រួសារដែលបានផ្តល់ចម្លើយទាក់ទងអាកាសធាតុ

| សីតុណ្ហភាព | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ក្តៅខ្លាំង | 396 | 82.5 |
| ត្រជាក់ខ្លាំង | 15 | 3.1 |
| ក្តៅល្មម | 64 | 13.3 |
| ត្រជាក់ល្មម | 5 | 1.0 |
| សរុប | 480 | 100.0 |

## រូបភាព ៣.១៨ ស្ថានភាពសីតុណ្ហភាព



# ជំពូក ៤
# របកគំហើញ និង សន្និដ្ឋាន

## ៤.១ របកគំហើញ

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១ នៅតាមខេត្តគោលដៅទាំង ២គឺ ខេត្តកំពង់ធំ និងខេត្តសៀមរាប ដែលផ្អែកលើទិន្នន័យទី២ ដែលទទួលបានពីប្រភពផ្សេងៗ និងទិន្នន័យទី១ ដោយការចុះសម្ភាសន៍ផ្ទាល់ដល់ទីតាំងជាក់ស្តែង បានបង្ហាញអំពីរបកគំហើញដូចខាងក្រោម៖

### ៤.១.១ កំណើនប្រជាជន ការធ្វើចំណាកស្រុក និង ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច

កំណើនប្រជាជនមានការកើនឡើងជាលំដាប់នៅទូទាំងប្រទេស រួមទាំងតំបន់ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប។ តាមការព្យាករណ៍ចំនួនប្រជាជននៅឆ្នាំ ២០៣០ សម្រាប់ទូទាំងប្រទេសនឹងកើនដល់ ១៨.៣៩០. ៦៨៣ នាក់ ក្នុងនោះខេត្តកំពង់ធំ នឹងកើនដល់ជាង ៧២៤.៤៥៦ នាក់ និង ខេត្តសៀមរាបនឹងកើនឡើងដល់ ១.៤១៤.៧២៧ នាក់ ។ ជាមួយកំណើនប្រជាជននេះ ការផ្លាស់ប្តូរទីលំនៅទូទាំងប្រទេស និងខេត្តទាំងពីរ មាននិន្នាការធ្លាក់ចុះ។ នៅទូទាំងប្រទេសបានធ្លាក់ចុះពី ៣១ ភាគរយនៅឆ្នាំ ១៩៩៨ មកត្រឹម ២២ ភាគរយនៅឆ្នាំ ២០១៩ ហើយខេត្តកំពង់ធំបានធ្លាក់ចុះពី ១៨ ភាគរយ មកត្រឹម ១០ភាគរយ និងខេត្តសៀមរាប បានធ្លាក់ចុះ ២៧ ភាគរយ នៅឆ្នាំ ១៩៩៨ មកត្រឹម ១៦ ភាគរយ។ ជាមួយគ្នានេះ ផងដែរ ការធ្វើចំណាកស្រុកក្នុងប្រទេសមានជាង ៩០ ភាគរយ ដើម្បីស្វែងរកការងារធ្វើ ហើយភាគច្រើនមកធ្វើការនៅរាជធានីភ្នំពេញ ខណៈដែលចំណាកស្រុកក្រៅប្រទេសមានក្រោម ១០ ភាគរយ ហើយភាគច្រើនស្វែងរកការងារធ្វើ។ ការធ្វើចំណាកស្រុកនេះ ក៏មានការពាក់ព័ន្ធនឹងការងារកសិកម្មដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះរាំងស្ងួត ដែលប៉ះពាល់ដល់ការដាំដំណាំផ្សេង និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត។ ទន្ទឹមនឹងនេះផងដែរ ការចូលរួមកកម្លាំងពលកម្ម ទូទាំងប្រទេស និងខេត្តទាំងពីរ គឺការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកិសកម្មមានការថយចុះ ចំណែកវិស័យឧស្សាហកម្ម និងសេវាកម្មគឺមានការកើនឡើង។

### ៤.១.២ តំបន់ទីប្រជុំជនមានការកើនឡើង

ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន សម្រាប់ទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ មានចំនួន ១៥,៧ ភាគរយ នៅឆ្នាំ ២០០៨ មានចំនួន ១៩,៥ ភាគរយ និងនៅឆ្នាំ ២០១៩ បានកើនឡើងដល់ ៣៩,៤ ភាគរយ ហើយរំពឹងថានៅ

ឆ្នាំ ២០៣០ អាចកើនឡើងដល់ ៤៣ ភាគរយ។ ខេត្តកំពង់ធំ ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនបានកើនឡើងពី ២,២ភាគរយនៅឆ្នាំ ១៩៩៨ បានកើនឡើងដល់ ១០,៣ភាគរយ នៅឆ្នាំ ២០១៩ ខណៈដែលខេត្តសៀមរាបក៏មានការកើនឡើងផងដែរ នៅឆ្នាំ ១៩៩៨ មានចំនួន ១៧,២ ភាគរយ បានកើនឡើងដល់ ៣០,៦ ភាគរយ នៅឆ្នាំ ២០១៩។ ការកើនឡើងនេះ គឺដោយសារការអភិវឌ្ឍ និងម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជា បានកែប្រែតំបន់រដ្ឋបាលមួយចំនួនស្របតាមការអភិវឌ្ឍរបស់ប្រទេស ប៉ុន្តែជាក្តីបារម្ភផងដែរ ទាក់ទងទៅនឹងសន្តិសុខស្បៀង សម្រាប់ប្រទេសកម្ពុជាដោយសារដីដែលផលិតដំណាំកសិកម្ម និងដាំណាំស្រូវត្រូវបានបង្វែរសង់លំនៅដ្ឋាន និងធ្វើការអភិវឌ្ឍផ្សេងៗ និងផលប៉ះពាល់ដល់បរិស្ថានផ្សេងៗ។

### ៤.១.៣ បរិស្ថាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា គម្របព្រៃមានការថយចុះខ្លាំងចំនួនពី ៧៣,៤ ភាគរយ នៅឆ្នាំ ១៩៦៥ មកត្រឹម ៤៦,៩ ភាគរយនៅឆ្នាំ ២០១៨។ បញ្ហាប្រមូលសំរាមការទុកដាក់សំរាមនៅទូទាំងប្រទេស ខេត្តកំពង់ធំ និងខេត្តសៀមរាបនៅមានចំនួនតិចតួចនៅឡើយ។ ការប្រើប្រាស់ទឹកស្អាត និងការប្រើប្រាស់បង្គន់អនាម័យរបស់ប្រជាជននៅមានយល់ដឹងជាងមុនបន្តិចនៅទូទាំងប្រទេស ខេត្តកំពង់ធំ និងខេត្តសៀមរាប ខណៈដែលការបញ្ចេញទឹកកខ្វក់ក៏មានការកើនឡើងផងដែរ ។ លើសពីនេះទៀត ផលប៉ះពាល់ដោយសារការប្រើប្រាស់ថ្នាំគីមី និងថ្នាំបាញ់សម្លាប់សត្វល្អិតមានផលប៉ះពាល់ក៏កើតមានផងដែរ ។

### ៤.១.៤ គ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ អគ្គីភ័យ និង ខ្យល់ព្យុះ គឺបានកើតឡើងប្រាកដមែន តាមរយៈនៃកាសិក្សានេះ ក្នុងនោះការស្លាប់ដោយសារទឹកជំនន់មានចំនួនច្រើនជាងគេផ្អែកលើទិន្នន័យទី ២ ។ ការទទួលបានប្រភពព័ត៌មានអំពីគ្រោះមហន្តរាយតាមរយៈទូរស័ព្ទដៃមានចំនួនច្រើនជាងគេ អាជ្ញាធរមូលដ្ឋាន ទូរទស្សន៍ វិទ្យុ និងប្រភពផ្សេងៗតាមលំដាប់រៀង។ គ្រោះមហន្តរាយគ្រោះខ្យល់ព្យុះមានផលប៉ះពាល់ខ្លាំងជាងគេ បន្ទាប់មកគ្រោះរាំងស្ងួត និងទឹកជំនន់តាមលំដាប់រៀង បានកើតឡើងក្នុងតំបន់ដែលបានចុះស្រង់ទិន្នន័យ។ ក្នុងគ្រោះមហន្តរាយក៏បានរកឃើញការឆ្លងជំងឺកូវីដ ១៩ គ្រុនឈាម គ្រុនឈឹក ការបាក់រលំអគារ និងគ្រោះអគ្គីភ័យក៏បានកើតឡើងនៅខេត្តផ្សេង តាមរយៈការប្រមូលនៃទិន្នន័យទី២ ក្នុងអំឡុងពេលសិក្សានេះផងដែរ។

### ៤.១.៥ ការប្រែប្រួលអាកាសធាតុ

បើទោះបី ការអនុវត្តគម្រោងនេះពុំមានឧបករណ៍ទំនើបសម្រាប់ស្រង់ទិន្នន័យតាមរយៈផ្កាយរណប ឬ ដ្រូនពិតមែន តែតាមរយៈការសិក្សាស្រាវជ្រាវនៃប្រភពទិន្នន័យផ្សេងៗ និងការចុះសម្ភាសន៍ស្រង់ទិន្នន័យផ្ទាល់ដល់មូលដ្ឋានជាក់ស្តែងរកឃើញថាៈ

- កំពស់ទឹកភ្លៀងមានការថយចុះ
- កំពស់ទឹកទន្លេមគង្គក៏មានការថយចុះ
- ភ្លៀងធ្លាក់មិនទៀងទាត់
- សីតុណ្ហភាពមានការប្រែប្រួលជាពិសេសមានកម្តៅខ្លាំងខុសពីប្រក្រតី។

## ៤.២ សន្និដ្ឋាន

តាមរយៈលទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០២១ នៅក្នុងខេត្តកំពង់ធំ និង ខេត្តសៀមរាប ដោយផ្អែកលើសូចនាករទាំងឡាយដែលប្រមូលបានពីប្រភពផ្សេងៗ និងការចុះសម្ភាសន៍ផ្ទាល់ អាចសន្និដ្ឋានបានថា បញ្ហាប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុពិតជាបានកើតឡើងនៅក្នុងតំបន់ដែលស្ថិតនៅក្នុងក្របខណ្ឌនៃធ្វើអង្កេតនេះពិតប្រាកដមែន ដែលត្រូវរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់មានវិធានការបង្ការផ្សេងៗស្របតាមការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុជាសកល។ នៅក្នុងផ្នែកគ្រោះមហន្តរាយ គឺមានគ្រោះមហន្តរាយទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ និងខ្យល់ព្យុះ ដែលក្នុងនោះគ្រោះមហន្តរាយប៉ះពាល់ដល់គ្រួសារប្រជាជននៅក្នុងខេត្តទាំង២គឺ គ្រោះរាំងស្ងួត មានទឹកជំនន់ និងខ្យល់ព្យុះ ខណៈដែលគ្រោះមហន្តរាយដូចជាជំងឺឆ្លងកូវីដ១៩ ជំងឺគ្រុនឈាម និងជំងឺគ្រុនឈឺក ការបាក់រលំអគារ និងអគ្គីភ័យក៏បានកើតឡើងនៅក្នុងខេត្តផ្សេងៗផងដែរ តែមិនបានកើតឡើងក្នុងតំបន់ដែលយើងសិក្សានោះឡើយ។

សរុបមក លទ្ធផលនេះ បានបង្ហាញអំពីសមិទ្ធិផលថ្មីមួយទៀតលើកទី ៣ បន្ទាប់ពីបានធ្វើការវិភាគរបាយការណ៍ឆ្នាំ ២០១៩ មក នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ កន្លងទៅ ហើយជាទិន្នន័យនេះ ពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំគោលនយោបាយជាតិ និងការធ្វើផែនការ ដែលទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ ដែលបានកើតឡើង និងការប្រែប្រួលអាកាសធាតុ បន្ថែមពីលើទិន្នន័យពីប្រភពផ្សេងៗទៀតដែលមានស្រាប់។

# ឯកសារយោង


១. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

២. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជាពលរដ្ឋកម្ពុជាចន្លោះជំរឿនឆ្នាំ ២០០៤* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

៣. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០៩។

៤. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *អង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០១៣ របាយចុងក្រោយ* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៥. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តួលេខបណ្ដោះអាសន្ននៃចំនួនប្រជាជនសរុប* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៦. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៨។

៧. មន្ទីរផែនការរាជធានី ខេត្ត៖ *ទិន្នន័យមូលដ្ឋាន* ២០១៦, ២០១៧ និង ២០១៨, មន្ទីរផែនការរាជធានី ខេត្ត។

៨. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ៖ *របាយការណ៍ស្ដីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ* ២០២១, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៩. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៦*,ក្រសួងធនធានទឹក និងឧតុនិយម។

១០. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៧*,ក្រសួងធនធានទឹក និងឧតុនិយម។

១១. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៨*,ក្រសួងធនធានទឹក និងឧតុនិយម។

១២. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៩*,ក្រសួងធនធានទឹក និងឧតុនិយម។

១៣. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០២០*,ក្រសួងធនធានទឹក និងឧតុនិយម។

១៤. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០២១*,ក្រសួងធនធានទឹក និងឧតុនិយម។

១៥. ក្រសួងបរិស្ថាន៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ ២០១៩,* ក្រសួងបរិស្ថាន។
១៦. ក្រសួងបរិស្ថាន៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី ៤ ឆ្នាំ ២០២១,* ក្រសួងបរិស្ថាន។
១៧. National Institute of Statistics, Ministry of Planning, *General Population Census of Cambodia 2008, Analysis of the Census Results, Report 12 Population Projection of Cambodia, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.
១៨. National Institute of Statistics, Ministry of Planning, *Reclassification of Urban Areas in Cambodia 2011, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាបសម្រាប់
# អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១

## (សម្រាប់មេភូមិ)

## រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការភពផែនដី
វិទ្យាស្ថានជាតិស្ថិតិ

# ក្រសួងផែនការ

រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០២១

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត............................................... ☐☐
ក្រុង/ស្រុក/ខណ្ឌ........................................... ☐☐
ឃុំ/សង្កាត់.................................................. ☐☐
ភូមិ/មណ្ឌល.................................................. ☐☐
ទីប្រជុំជន/ជនបទ.......................................... ☐☐
កាលបរិច្ឆេទចុះស្រង់ទិន្នន័យៈ ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០២១
ឈ្មោះមេភូមិ .......................................ភេទ ............ អាយុ........
លេខទូរស័ព្ទមេភូមិ ....................................
ឈ្មោះមន្ត្រីសម្ភាសន៍ ................................................

២. **ព័ត៌មានអំពីគ្រួសារក្នុងភូមិ៖**

| ល.រ | ប្រភេទទិន្នន័យ | ២០២០ | ២០២១ |
|---|---|---|---|
| ១ | ចំនួនប្រជាជនសរុប | | |
| ២ | ចំនួនគ្រួសារសរុប | | |
| ៣ | ចំនួនគ្រួសារទទួលបានទឹកស្អាត | | |
| ៤ | ចំនួនគ្រួសារដែលប្រើប្រាស់អគ្គិសនី | | |
| ៥ | ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ | | |
| ៦ | ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្ម | | |
| ៧ | ចំនួនប្រជាជនធ្វើការក្នុងវិស័យឧស្សាហកម្ម | | |
| ៨ | ចំនួនប្រជាជនធ្វើការក្នុងវិស័យសេវាកម្ម | | |
| ៩ | ចំនួនរោងចក្រសហគ្រាសដែលមានកម្មករចាប់ពី ១៥នាក់ឡើង | | |

៣. **ព័ត៌មានអំពីគ្រោះមហន្តរាយ ៖**

៣.១ តើប្រជាជនក្នុងភូមិបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ ?

ក. គ្មាន.......................................... ☐
ខ. មាន .......................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន...........
២. តាមរយៈទូរទស្សន៍....................
៣. តាមរយៈវិទ្យុ............................
៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ.................................
៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ...........................
៦. តាមការសែត...........................................................
៧. តាមប្រភពផ្សេង (បញ្ជាក់)...........................................

៣.២ តើមានចំនួនសម្ភារៈប៉ុន្មានដែលខូចខាត ដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០២០ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ "

ក. ចំនួនផ្ទះសម្បែងដែលខូចខាត
ខ. ចំនួនយានយន្តដែលខូចខាតៈ ម៉ូតូ ឡាន
. គ.ចំនួនសម្ភារៈខូចខាតផ្សេងៗ (បញ្ជាក់).......................................

៣.៣ តើមានជនរងគ្រោះដោយសាររន្ទះបាញ់ប៉ុន្មាននាក់ក្នុង ២០២០ កន្លងមក ? បើគ្មាន សូមចុះលេខសូន្យ " ០ "

៣.៤ តើមានចំនួនគ្រួសារប៉ុន្មានទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០២០ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ "

៣.៥ តើមានចំនួនគ្រួសារប៉ុន្មានដែលខ្វះខាតទឹកប្រើប្រាស់ ដោយសារគ្រោះរាំងស្ងួតក្នុងឆ្នាំ ២០២០ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ "

៣.៦ តើមានចំនួនគ្រួសារប៉ុន្មានដែលធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំងទន្លេ ស្ទឹង ព្រែក ... ក្នុងឆ្នាំ ២០២០ កន្លងមកដែរ ឬ ទេ? បើគ្មាន សូមចុះលេខសូន្យ " ០ "

## ៤. ផលប៉ះពាល់បរិស្ថានក្នុងភូមិ

៤.១ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីកាកសំណល់ សិប្បកម្ម ឬ រោងចក្រ
៤.២ ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកសំអុយ

## ៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើតាមការកត់សំគាល់របស់លោកពូអ្នកមីងឃើញថាមានការប្រែប្រួលទាក់ទងនឹងអាកាសធាតុដូចម្ដេចដែរ?

| | | | | |
|---|---|---|---|---|
| ក. សីតុណ្ហភាព | ប្រែប្រួល | | មិនប្រែប្រួល | |
| ខ. ទឹកភ្លៀង | ទៀងទាត់ | | មិនទៀងទាត់ | |
| គ. គ្រោះរាំងស្ងួត | មានរាំងស្ងួត | | មិនមានរាំងស្ងួត | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ នៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាបសម្រាប់ អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២១

## (សម្រាប់គ្រួសារ)

**រៀបចំដោយ៖**

អង្គភាពក្រុមសង្កេតការភពផែនដី
វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០២១

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត............................................... ☐☐
ក្រុង/ស្រុក/ខណ្ឌ.......................................... ☐☐
ឃុំ/សង្កាត់................................................. ☐☐
ភូមិ/មណ្ឌល................................................ ☐☐
ទីប្រជុំ/ជនបទ ............................................. ☐☐

កាលបរិច្ឆេទចុះស្រង់ទិន្នន័យ: ថ្ងៃទី ........ ខែ សីហា ឆ្នាំ ២០២១
ឈ្មោះអ្នកតបសម្ភាសន៍ .............................................
លេខទូរស័ព្ទអ្នកតបសម្ភាសន៍ .....................................
ឈ្មោះមន្ត្រីសម្ភាសន៍ .................................................

**២. ព័ត៌មានទូទៅអំពីគ្រួសារ៖**

**២.១ ចំនួនសមាជិកគ្រួសារ (២០២១)**

ឈ្មោះមេគ្រួសារ ....................................... ភេទ .......... អាយុ ...........

| សមាជិក អចិន្ត្រៃយ៍ | | | សមាជិកចំណាកស្រុក | | | ចំណាកស្រុកក្នុប្រទេស | | | ចំណាកស្រុកក្រៅប្រទេស | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| | | | | | | | | | | | |

**២.១.១ មុខរបរចម្បងរបស់សមាជិកគ្រួសារក្នុងរយៈពេល ១២ ខែ កន្លងមក(២០២១)**

ក. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យកសិកម្ម (ដាំដំណាំ និងចិញ្ចឹមសត្វ) ៖
ប្រុស ☐ ស្រី ☐ សរុប ☐

ខ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការនេសាទ៖
ប្រុស ☐ ស្រី ☐ សរុប ☐

គ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យសេវាកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.២ សមាជិកគ្រួសារធ្វើការងារក្នុងផ្នែកណាមួយក្នុងរយៈពេល ១២ ខែ កន្លងមក (២០១៩)**

ក.រដ្ឋាភិបាល ប្រុស ☐ ស្រី ☐ សរុប ☐
ខ. អង្គភាពស្វយ័ត ប្រុស ☐ ស្រី ☐ សរុប ☐
គ. ផ្នែកឯកជនខ្មែរ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ.ផ្នែកឯកជនបរទេស ប្រុស ☐ ស្រី ☐ សរុប ☐

ង. ស្ថាប័នមិនយកប្រាក់ចំណេញ ប្រុស ☐ ស្រី ☐ សរុប ☐

ច. ផ្នែកគ្រួសារ ប្រុស ☐ ស្រី ☐ សរុប ☐

ឆ.ស្ថានទូត/ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយបរទេស

ប្រុស ☐ ស្រី ☐ សរុប ☐

ជ. ផ្សេងៗ...............................ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.៣ ចំណាកស្រុកក្នុងប្រទេស (២០២១)**

| ឈ្មោះរាជធានី-ខេត្ត | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្នុងប្រទេស) ចាប់ ៦ ខែឡើង | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

ក. មូលហេតុចំណាកស្រុកក្នុងប្រទេស

| មូលហេតុ | ចំនួនសមាជិកចំណាកស្រុក (ក្នុងប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| សរុប | | | |

## ២.១.៤ ចំណាកស្រុកក្រៅប្រទេស (២០២១)

| ឈ្មោះប្រទេស | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

ក. មូលហេតុចំណាកស្រុកក្រៅប្រទេស

| មូលហេតុ | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| **សរុប** | | | |

## ២.២ មុខរបររបស់សមាជិកគ្រួសារ (២០២១)

| មុខរបរចម្បងៗ | ចំនួនសមាជិកគ្រួសារដែលបានចូលរួម | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| **សរុប** | | | |

## ៣. ព័ត៌មានបរិស្ថានអំពីគ្រួសារ

១=មាន ២=គ្មាន

| ល.រ | ប្រភេទប៉ះពាល់បរិស្ថាន | ២០២០ | ២០២១ |
|---|---|---|---|
| ១ | បង្គន់អនាម័យ | | |
| ២ | សេវាប្រមូលសំរាម | | |
| ៣ | ទីតាំងចោលសំរាម | | |
| ៤ | ទីតាំងទុកដាក់សំរាមនៅក្នុងបរិវេណផ្ទះ | | |
| ៥ | ផលប៉ះពាល់ពីការចោលសំរាម | | |
| ៦ | ផលប៉ះពាល់ពីកាកសំណល់សិប្បកម្ម/រោងចក្រ | | |
| ៧ | ផលប៉ះពាល់បង្ហូរកាកសំណល់ចូលក្នុងទឹក | | |
| ៨ | ផលប៉ះពាល់ថ្នាំបាញ់សម្លាប់សត្វល្អិត | | |
| ៩ | ផលប៉ះពាល់ការប្រើប្រាស់ជីគីមី | | |
| ១០ | កាប់បំផ្លាញព្រៃឈើ | | |
| ១១ | កាប់បំផ្លាញព្រៃលិចទឹក | | |
| ១២ | ផ្សេងៗ (បញ្ជាក់) | | |

## ៤. គ្រោះមហន្តរាយ

៤.១ តើអ្នកបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ? ☑

ក. គ្មាន...................................... ☐

ខ. មាន.......................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន............ ☐

២. តាមរយៈទូរទស្សន៍..................... ☐

៣. តាមរយៈវិទ្យុ.............................. ☐

៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ.................................. ☐

៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ............................ ☐

៦. តាមការសែត................................................................. ☐

៧. តាមប្រភពផ្សេង (បញ្ជាក់)............................................ ☐

៤.២ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ២០២១ កន្លងមក?

បាទ/ចាស ☐ ទេ ☐

- បើបាទ/ចាស សូមបញ្ជាក់ពីប្រភេទនៃការទទួលរងគ្រោះ៖

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតទ្រព្យសម្បត្តិ (កង់, ម៉ូតូ, ឡាន...) ☐

គ. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

ង. ផ្សេងៗសូមបញ្ជាក់(.......................................................)

៤.៣ តើសមាជិកគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ២០២១ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៣)*

ក. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ខ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

៤.៤ តើមានសត្វពាហនៈនៅក្នុងគ្រួសារអ្នកដែលទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ ២០២១ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៤)*

ក. ចំនួនសត្វពាហនៈស្លាប់ ☐

ខ. ចំនួនសត្វផ្សេងៗដែលស្លាប់សូមបញ្ជាក់(.......................................................) ☐

៤.៥ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០២១ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៥)*

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតដំណាំកសិកម្ម ☐

គ. ប៉ះពាល់ដល់សត្វពាហនៈ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.......................................................)

៤.៦ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួត ឬ ខ្វះខាតទឹក ដែរ ឬ ទេក្នុងឆ្នាំ ២០២១ កន្លងមក?

☐ ☐

បាទ/ចាស ទេ

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៦)*

ក. ខូចខាតដំណាំកសិកម្ម ☐

ខ. ប៉ះពាល់ដល់សត្វពាហនៈ ☐

គ. ខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(.......................................................) ☐

**៤.៧ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំង ទន្លេ បឹង ស្ទឹង ព្រែក ក្នុងឆ្នាំ ២០២១ កន្លងមកដែរ ឬ ទេ?**

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៥)*

ក. បាត់បង់ផ្ទះសម្បែង ☐

ខ. បាត់បង់អាយុជីវិត ☐

គ. ផ្សេងៗសូមបញ្ជាក់(.......................................................) ☐

**៥. ការប្រែប្រួលអាកាសធាតុ**

**៥.១ តើក្នុងឆ្នាំ ២០២១ កន្លងមក ស្ថានភាពទឹកភ្លៀងយ៉ាងដូចម្តេចដែរនៅក្នុងភូមិ?**

ក. ទៀងទាត់ ☐

ខ. មិនទៀងទាត់ ☐

គ. ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះ ☐

**៥.២ តើសីតុណ្ហភាពក្នុងឆ្នាំ ២០២១ កន្លងមក មានលក្ខណៈយ៉ាងដូចម្តេចដែរនៅក្នុងភូមិ?**

ក. ក្តៅខ្លាំង ☐

ខ. ត្រជាក់ខ្លាំង ☐

គ. ក្តៅល្មម ☐

ឃ. ត្រជាក់ល្មម ☐